# ភាគទី២

## អំពីបញ្ហាមួយចំនួនដែលលេចចេញឡើងក្រោយឆ្នាំ១៩៧៩

ភាគទីមួយនៃជំពូកនេះ ជាប្រវត្តិនៃដំណើរមួយយ៉ាងវែង តែដោយអំណត់អត់ធន់ឈានទៅស្ដាបនាបក្សនយោបាយខ្មែរមួយ ដែលគ្មានទិសដៅអ្វី ក្រៅពីរំដោះខ្លួនឲ្យចេញផុតពីអាណាព្យាបាលវៀតណាមតែប៉ុណ្ណោះទេ។ គឺអាណាព្យាបាលដែលបានដាក់មកលើខ្មែរ តាំងពី៩ឆ្នាំមុននៃកិច្ចព្រមព្រៀងហ្សឺណែវឆ្នាំ១៩៥៤។ ជាដំណើរមួយបោះជំហានដាច់ខាតឈានទៅរកឯករាជ្យ ប៉ុន្តែដោយមានការប្រុងប្រយ័ត្នបំផុតជៀសវាងមិនឲ្យមានអ្វីដែលអាចប៉ះពាល់ដល់សាមគ្គីភាពរវាងប្រជាជនទាំងពីរ ដែលវាសនាតម្រូវឲ្យរួមគ្នាប្រយុទ្ធប្រឆាំង និងសត្រូវរួម។ ប្រជាជនកម្ពុជាយល់ស្របធ្វើជាសម្ព័ន្ធមិត្តជាមួយវៀតណាម ដែលធំជាងខ្លួន ប៉ុន្តែមិនព្រមនៅក្រោមបង្គាប់វៀតណាមទៀតទេ។ ប៉ុន្តែនៅក្នុងរយៈពេលប៉ុន្មានទសវត្សរ៍តៗមក ដោយសារតែការតម្រូវនៃការតស៊ូរបស់វៀតណាមផ្ទាល់ វៀតណាមបានប្រែក្លាយសកម្មភាពយោធារបស់គេនៅកម្ពុជា ឲ្យទៅជាបូជនីយកិច្ចមួយខាងមនោគមវិជ្ជា ហើយដោយសឹងតែមិនដឹងខ្លួនផង ក៏បានប្រព្រឹត្តដូចដែលខ្លួនមានបេសកកម្មមួយនាំយកអារ្យធម៌មួយមកឲ្យខ្មែរ ដូចសម័យអធិរាជមីងម៉ាងនាសតវត្សទី១៩។ ហើយនៅរវាងផ្នែកទី២នៃទសវត្សរ៍ឆ្នាំ៦០ វៀតណាមនៅតែបន្តទទូចឲ្យប្រជាជនខ្មែរដើរតាមផ្លូវមួយ ដែលនាំឲ្យគេដើរឆ្ពោះទៅរកគ្រោះថ្នាក់ដល់ស្លាប់ខ្លួន។ ចំណែកឯវៀតណាមវិញក៏គ្មានលទ្ធភាពអ្វីនឹងមកជួយគេវិញផងទេ។ នេះហើយដែលខ្មែរមិនព្រមទទួលតាម។ នេះហើយដែលវៀតណាមយល់ថា ជាការព្រហើនកោងកាច។ មិនគ្រាន់តែព្រហើនកោងកាចទេ តែធ្វើឲ្យប៉ះពាល់ដល់កម្លាំងគេ ដល់ផលប្រយោជន៍គេធ្ងន់ធ្ងរណាស់។ ឧទាហរណ៍កាលពីឆ្នាំ១៩៦៨-៦៩ អាមេរិកចូលទៅវៃគេនៅរតនៈគិរី មណ្ឌលគិរី ទម្លាក់គ្រាប់បែកបេ៥២លើជម្រករបស់គេ ក៏ដោយសារតែប៉ុល

ពតមិនព្រមស្តាប់គេ។ គេមិនព្រមរកយល់សភាពការណ៍វាយ៉ាងណា។ ដោយសាររួចពីគ្រោះថ្នាក់ទេ គឺគេចោទយ៉ាងនេះតែម្តង។ ធ្ងន់ធ្ងរជាងនេះទៅទៀត តាំងពីក្រោយឆ្នាំ១៩៧០ ក្រោយរដ្ឋប្រហារ កម្ពុជាត្រូវបានមកក្នុងកណ្តាប់ដៃគេទៅហើយ។ តែគេត្រូវខកខានទៅវិញ ដោយសារតែប៉ុលពត និងប.ក.ក.។ នេះហើយដែលក្រោយពីប្រទេសទាំងពីរបានទទួលជ័យជម្នះរៀងៗខ្លួន នៅពេលដែលវៀតណាមស្រឡះដៃជើង វៀតណាមសម្រេចបញ្ចប់ប៉ុលពត និង ប.ក.ក។ ប៉ុន្តែវៀតណាមមានវិធីប៉ិនប្រសប់ជាងសហភាពសូវៀត នៅពេលដែលសហភាពសូវៀត ដាក់ទណ្ឌកម្មលើប្រទេសហុងគ្រី កាលពីឆ្នាំ១៩៥៦។ ឯវៀតណាមវិញ គេយករូបភាពជម្លោះព្រំដែនមកបិទបាំងទិសដៅពិតរបស់គេ។ ដូច្នេះហើយ បានជានៅកម្ពុជាមិនមានអ្នកណាដឹង មិនមានអ្នកណាយល់ទេ អំពីជម្លោះព្រំដែនទឹក អំពីសង្គ្រាមរវាងប្រទេសទាំងពីរ តើអ្នកណាខុស អ្នកណាត្រូវ?។ ផ្ទុយទៅវិញគេឃើញតែកម្ពុជាប្រជាធិបតេយ្យអាក្រក់ ហើយគេមិនឆ្ងល់ហេតុអ្វីបានជាប្រទេសតូច ហ៊ានទៅរករឿងប្រទេសធំយ៉ាងនេះ? ហើយគេក៏មិនយល់ មិនទាន់បានស្រាវជ្រាវហ្មត់ចត់ តើឱសានវាទរបស់វៀតណាម អាចជះបច្ច័យយ៉ាងណា លើបញ្ហាផ្ទៃក្នុងកម្ពុជាទេ។

យើងសាកល្បងពិនិត្យរឿងល្អិតទាក់ទងនិងរឿងនេះ។ ទន្ទឹមនឹងនេះក៏មានបញ្ហាមួយចំនួនទៀត ដែលដោយផ្ទាល់ក្តី ដោយប្រយោលក្តីទាក់ទងនឹងរឿងនេះដែរ។



## អំពីជម្លោះជាមួយវៀតណាម៖ តើអ្នកណាជាអ្នកដើមរឿង?

### ទី១-តើរឿង ដែលវៀតណាមទាមទារឲ្យកែប្រែព្រំដែនទឹកជារឿងអ្វី?

ដើម្បីយល់ដើមរឿងនៃសង្គ្រាមរវាងកម្ពុជាប្រជាធិបតេយ្យ និងសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យវៀតណាម ចាំបាច់ត្រូវយល់ថា ការទាមទាររបស់វៀតណាមឲ្យកែប្រែព្រំដែនសមុទ្រនៅខែឧសភាឆ្នាំ១៩៧៦ ជាក់ស្តែងគឺជាឱសានវាទមួយ ដែលវៀតណាមដាក់មកលើកម្ពុជាប្រជាធិបតេយ្យ។

ឆ្លើយគោរពតាម ក៏នៅតែងាប់។ ពីព្រោះបក្សកុម្មុយនីស្តកម្ពុជានឹងត្រូវផ្ទុះបាក់បែកខ្ចាត់ខ្ចាយ ដោយសារតែសមាជិកមួយចំនួនច្រើនច្បាស់ជាមិនព្រម។

ឆ្លើយបដិសេធ កម្ពុជាប្រជាធិបតេយ្យច្បាស់ជាត្រូវមានរឿងតាមព្រំដែនរហូតដល់ផ្ទុះសង្គ្រាម ដោយរកមិនឃើញ តើអ្នកណារំលោភលើអ្នកណាទេ។

បញ្ហានេះមិនត្រូវមានទាល់តែសោះ ពីព្រោះក្នុងការចរចារវាងកម្ពុជាជំនាន់សម្តេចនរោត្តម សីហនុជាមួយរណសិរ្សរំដោះវៀតណាមខាងត្បូងកាលពីឆ្នាំ១៩៦៧ ខ្សែបន្ទាត់ប្រេវីយេបានត្រូវទទួលស្គាល់ថា ជា "ព្រំដែនបច្ចុប្បន្ន" បែងចែកសមុទ្ររវាងប្រទេសទាំងពីររួចអស់ហើយ។[១៦៣]

### ទី២-ឯកសារជាគន្លឹះ កំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍នៃប.ក.ក. ថ្ងៃ១៤ឧសភាឆ្នាំ១៩៧៦

ឯកសារនេះមានផ្សាយទាំងស្រុងក្នុងសៀវភៅរបស់លោកបែន គៀរណាន់:។[១៦៤] នៅក្នុងឯកសារនេះ លោកណីសារ៉ាន់ (ហៅយ៉ា) ប្រធានគណៈ

---

[១៦៣] ណាយ៉ាន់ ចាន់ដា "បងប្អូនសត្រូវនឹងគ្នា" ទំព័រ៣៣

[១៦៤] បែន គៀរណាន់ "របបប៉ុល ពត" ទំព័រ១១៥-១១៨

ប្រតិភូខ្មែរបានរៀបរាប់ខ្លឹមសារដែលប្រធានគណៈប្រតិភូវៀតណាម ឈ្មោះ ផាន់ ហ៊ាន បាននិយាយពីព្រឹកដូចតទៅ: "ថ្មីៗនេះកងទ័ពខ្មែរបានចូលវាយក្នុងដីរបស់វៀតណាម" ថា "ខ្សែបន្ទាត់ប្រេវីយេគ្មានមូលដ្ឋានទេ" ថា "បើវៀតណាមសុខចិត្តទទួលយក គឺជាការប៉ះពាល់អធិបតេយ្យភាពវៀតណាម" ហើយថា "គោលជំហររបស់ វៀតណាមពីមុនមកគ្មានមូលដ្ឋានច្បាប់ទាល់តែសោះ ពីព្រោះគ្មានហត្ថលេខា" ថា "ព្រំដែនទឹកត្រូវគូសបែងចែកពាក់កណ្ដាលម្នាក់... ទើបសមរម្យ..."។

ឯកសារនេះបញ្ជាក់ឲ្យឃើញថា អ្នកដឹកនាំខ្មែរក្រហម កំពុងស្ថិតនៅក្រោមការគៀបសង្កត់របស់វៀតណាម ហើយកំពុងព្រួយបារម្ភយ៉ាងខ្លាំងៗ ខ្ញុំដែលចូលរួមស្ដាប់នឹងគេដែរ ខ្ញុំក៏មានការព្រួយបារម្ភដូចគេដែរ។

ឧទាហរណ៍ គេអាចអានពាក្យរបស់លោក នួន ជា ដែលគាត់មានប្រសាសន៍ថា "វាចង់សម្លាប់យើងតាមការចរចារ" "ដូច្នេះយើងត្រូវសុខចិត្តទទួលយកសភាពការណ៍បច្ចុប្បន្ន គឺសភាពការណ៍ដែលព្រំដែនមិនទាន់បានកំណត់ច្បាស់លាស់ជាដាច់ដដែកគ្នាមិនចេះចប់។ ទើបលោក វន វេត មានប្រសាសន៍ថា "តាមមើលវាមិនងាយថយទេ។ ចរចាតទៅទៀតមិនបានផលអ្វីទេ។ ជាទស្សនៈរបស់វា វាគិតថា វាជាប្រទេសធំ ហើយវាមិនព្រមឱនក្បាលទទួលការស្នើរបស់យើងទេ។ កម្ពុជាយើង យើងខំការពារផលប្រយោជន៍យើង ឯវាវៀតណាម វាស្វែងរកចំណេញពីយើងជាប់ជានិច្ច"។ ហើយលោក វន វេត ក៏យល់ស្របថា បញ្ចប់ការចរចាល្អជាង។ គាត់ថា "ដូច្នេះ យើងផ្អាកការចរចារក្សាសភាពការណ៍ឲ្យនៅហ្នឹងហ្ន៎ ជៀសវាងកុំឲ្យមានការប៉ះទង្គិច ដើម្បីយើងរក្សាការរួមរស់ដោយសន្តិភាព ទម្រាំដល់យើងមានកម្លាំងគ្រប់គ្រាន់ ដោយមានបាយហូបគ្រប់គ្រាន់។ ហើយគាត់បន្ថែមទៀតថា "យើងមិនអាចធ្វើយ៉ាងនេះបានងាយៗទេ។ តទៅមុខទៀតនឹងមានការប៉ះទង្គិចគ្នាតាមព្រំដែនទៀត"។ ទោះបីយ៉ាងនេះក៏ដោយ គាត់ក៏នៅរក្សាមតិឲ្យបញ្ចប់ការចរចា។



បន្តមកលោក សុន សេន ក៏ថ្លឹងថ្លែងឡើងចុះ ហើយក៏យល់ថា ត្រូវបញ្ចប់ការចរចា។ គាត់ក៏មានប្រសាសន៍ថា "ខ្ញុំយល់ស្របតាមបង (នួន ជា) ថា យើងត្រូវរកវិធី... ដើម្បីបញ្ចប់ការចរចាដោយរក្សាបរិយាកាសឲ្យនៅដដែល"។

ទើបលោកប៉ុលពត មានមតិ។ គាត់ចាប់ផ្ដើមដោយមានប្រសាសន៍ថា "គាត់មិនមានអ្វីខុសប្លែកពីអ្វីដែលបាននិយាយមកហើយទេ គាត់គ្រាន់តែចង់ចន្ថែមមតិខ្លះ។ "....នឹងមានទំនាស់ជាប្រចាំជាមួយវៀតណាមហើយ" ហើយយើងមិនល្ងង់រហូតដល់ថា មិនត្រូវមានទំនាស់នោះទេ.... ពេលនេះនឹងតៗទៅអនាគតចេះតែមានទំនាស់ហើយ។ យើងត្រូវពង្រឹងគោលជំហរយើង.... ទៅអនាគតបើយើងឈរឲ្យជាប់លើពីសោធន៍នេះ យើងចរចាជាមួយនរណាក៏បានដែរ។ ដូច្នេះនេះជាមេរៀនធំណាស់.... ទោះបីយើងដោះស្រាយបញ្ហាមិនទាន់បានក៏ដោយ ក៏យើងមានពិសោធន៍"។ ទើបលោក បែន គៀរណាន់កត់សម្គាល់ថា ដូច្នេះការចរចាមិនសំដៅដោះស្រាយបញ្ហាទេតែសំដៅរៀនសូត្រ។ ឯមេរៀនគឺថាមិនអាចចរចាជាមួយវៀតណាមបានទេ។ ពីរឿងមេរៀននេះមតិខ្ញុំខុសពីលោកបែន គៀរណាន់។ ខ្ញុំនឹងមានឱកាសត្រឡប់មកនិយាយពីរឿងនេះនៅពេលក្រោយទៀត។ តែឥឡូវនេះ យើងស្ដាប់មតិរបស់លោក ប៉ុល ពត តទៅទៀតសិន "...នៅកម្ពុជាគ្មានអ្វីដែលជាធម្មតាទេ នេះ គឺមកពីប្រវត្តិសាស្ត្ររបស់វៀតណាម... ការដែលពួកវាខិតខំយកចំណេញពីយើង គឺជាសកម្មភាពធម្មតារបស់ពួកវា... យុទ្ធសាស្ត្រវាតទីរបស់ពួកវា ដែលមិនចេះចប់ រារាំងមិនឲ្យទទួលខ្សែបន្ទាត់ប្រេវីយេរបស់យើងទេ... ដោយវាបង្ហាញខ្លួនវាជាប្រទេសធំ ដើម្បីសំឡុតកម្ពុជា វាបានទាញកាំភ្លើងភ្ជង់កយើង..."។

ទីចុងបំផុតលោក ប៉ុលពត ក៏ចូលដល់សេចក្ដីសន្និដ្ឋានរបស់គាត់ ហើយស្នើវិធានការដូចតទៅ៖ "យើងបានចូលមកដល់សភាពទាល់ច្រកមួយ បើយើងបន្តចរចាតទៅទៀត គឺគ្រោះថ្នាក់ណាស់ ពីព្រោះវាចង់ឲ្យយើងសម្បទាន

ឲ្យវា... បើយើងបន្តតាមផ្លូវនេះ គឺយើងចាញ់បោកវា ហើយវានឹងនាំយើងទៅរកការតឹងតែង ហើយយើងខាត...។ យើងបញ្ចប់វិញល្អជាង។ ប៉ុន្តែយើងបញ្ចប់តាមរបៀបណា? គួរយើងពិភាក្សាគ្នាពីរឿងនេះ។

"ខាងស្អែក នៅក្នុងចម្លើយរបស់យើង យើងត្រូវប្រាប់វាថា យើងត្រូវការមិត្តភាព និងសាមគ្គីភាព..... ប្រតិភូ ណីសារ៉ាន់ ត្រូវប្រាប់វាថា ការទាក់ទងរវាងកម្ពុជា និងវៀតណាម ត្រូវថែបំប៉ន និងកែលំអជាប់ជានិច្ច ហើយត្រូវបន្ថែមថា "ដោយឈរលើមូលដ្ឋាននេះ យើងមានជំនឿជឿជាក់ថា ទីចុងបំផុតយើងនឹងអាចដោះស្រាយបញ្ហាបាន.... គណៈប្រតិភូត្រូវបញ្ជាក់ថែមទៀតថា ព្រំដែនទាំងអស់រវាងប្រទេសយើងទាំងពីរ គឺបាពំងជាអ្នកគូរ ហើយប្រាប់វាថា យើងមិនសុខចិត្តទទួលយកខ្សែបន្ទាត់ពីរទេ ដើម្បីបែងចែកទឹកផ្សេង កោះផ្សេងនោះទេ យើងទទួលតែខ្សែបន្ទាត់មួយទេ"។

គេអាចសម្គាល់ឃើញថា ដូចហូរហែកន្លងមកដែរ ខ្ញុំមិនមានមតិអ្វីនឹងគេទេ។ ខ្ញុំដឹងថា ទោះបីខ្ញុំនិយាយ ក៏ខ្ញុំគ្មានអ្វីបន្ថែមលើសពីនេះទៀតទេ។ ខ្ញុំហួសចិត្តអំពីការ ដែលអ្នកដឹកនាំវៀតណាមហាមាត់និយាយ យ៉ាងនេះទៅកើត។ ចំពោះពួកគេពាក្យថា "មិត្តភាព" "សាមគ្គីភាព" គ្មានន័យអ្វីទាំងអស់។ គឺមានតែផលប្រយោជន៍ចំពោះមុខរបស់គេជាសំខាន់។

កន្លងមកថ្មីៗនេះសោះ គឺឈរលើមូលដ្ឋាននៃសេចក្តីថ្លែងការណ៍របស់គេនេះហើយដែលសម្តេចនរោត្តម សីហនុ ជួយគាំទ្រការតស៊ូរបស់វៀតណាម ដោយឲ្យគេបោះជំរកនៅក្នុងទឹកដីខ្មែរនៅតាមព្រំដែន ហើយថែមទាំងបានជួយរៀបចំឲ្យដឹកអាវុធ និងគ្រាប់រំសេវ តាមកំពង់ផែព្រះសីហនុថែមទៀត។ គឺដោយសារព្រះអង្គបានជួយការតស៊ូវៀតណាមយ៉ាងនេះហើយ បានជាព្រះអង្គត្រូវលោកលន់នល់ និងអាមេរិកធ្វើរដ្ឋប្រហារទម្លាក់ព្រះអង្គ។

ហើយបើប្រសិនជាខ្មែរក្រហម មិនអនុញ្ញាតឲ្យការតស៊ូវៀតណាមយកទឹកដីកម្ពុជាទៅធ្វើជាបង្អែកខាងក្រោយខ្នងរបស់ខ្លួនទេ មិនអនុញ្ញាតឲ្យទិញស្រូវអង្ករកម្ពុជាទៅចិញ្ចឹមកងទ័ពទេ តើវៀតណាមអាចរំដោះទឹកដីខាងត្បូងហើយបង្រួបបង្រួមជាតិបានទេ?



និយាយមួយម៉ាត់ ដើម្បី "មិត្តភាព" "ភាតរៈភាព" "សាមគ្គីភាព" នេះប្រជាជនកម្ពុជាបានបង្ហូរឈាមច្រើនណាស់។

ឥឡូវនេះស្រាប់តែគេមកនិយាយថា គោលជំហររបស់វៀតណាមពីមុនមក "គ្មានមូលដ្ឋានច្បាប់ទាល់តែសោះ ពីព្រោះគ្មានហត្ថលេខា"។

នេះហើយជាប្រវត្តិសាស្ត្រនៃការទាក់ទងរវាងប្រទេសទាំងពីរ និងបក្សទាំងពីរ។ ហេតុនេះហើយបានជាខ្ញុំខំសរសេរលាតត្រដាងប្រវត្តិសាស្ត្រនេះតាំងពីដើមដល់ចប់ ទោះបីខ្ញុំត្រូវប្រើភាសាខ្លះដែលឥឡូវនេះគេមិនសូវនិយាយក៏ដោយ។

### ទី៣-ព្រឹត្តិការណ៍ជាក់ស្តែង: ជម្លោះជាមួយវៀតណាមចាប់ផ្តើមតាំងពីឆ្នាំ១៩៧៥ម្ល៉េះ។

ក្នុងការជាក់ស្តែងការប៉ះទង្គិចគ្នារវាងកម្លាំងវៀតណាម និងខ្មែរក្រហមមិនដែលបានស្រាកស្រាន្តទេ ចាប់ពីថ្ងៃដែលយុទ្ធជនវៀតណាមចូលជ្រៅក្នុងប្រទេសនៅឆ្នាំ១៩៧០មក។ តាមការពិតទៅ ក្រោយរំដោះប្រទេសហើយ កម្ពុជាឥតបានស្គាល់សន្តិភាពទេ។

ក្នុងសៀវភៅរបស់លោកក្រោមចំណងជើងថា "បងទី១" លោកដេវិតឆាន់ឡែរបានស្រង់សេចក្តីសារភាពរបស់ លោក ជូ ជេត ដែលបាននិយាយអំពី "ការវាយប្រហារ" នៅកន្លែងផ្សេងៗ... និង ការបុករុកចូលជ្រៅនៅញ្ញៀសាននៅតាមព្រំដែននៅឆ្នាំ ១៩៧៦។[១៦៥]

ប៉ុន្តែលោកណី សារ៉ាន់ គាត់និយាយច្បាស់ជាងពីព្រោះលោកជាប់នឹងរឿងនេះផ្ទាល់។ ពីមុនឆ្នាំ១៩៧០ គាត់ជាកម្មាភិបាលមួយរូបសំខាន់នៃគណៈ

---

[១៦៥] ដេវិត ឆាន់ឡែរ "បងធំទីមួយ" ទំព័រ១៣៣

កម្មាធិការភូមិភាគ។ តែដល់ពេលកើតមានសង្គ្រាមក្រោយរដ្ឋប្រហារ គាត់ត្រូវដកទៅឲ្យជួយខាងសេនាធិការវិញ ដើម្បីទៅជួយទទួលអាវុធដែលវៀតណាមដឹកមកប្រគល់ឲ្យកម្លាំងតស៊ូកម្ពុជា នៅត្រឹមព្រំដែនកម្ពុជា-លាវតាមគោលការណ៍ខ្មែរផ្ដល់ទិកដីជាបង្អែកខាងក្រោយ និងលក់ស្បៀងដល់កម្លាំងតស៊ូវៀតណាម វៀតណាមជួយដឹកជញ្ជូនឲ្យកម្លាំងតស៊ូកម្ពុជា។ ដល់ក្រោយរំដោះ (ក្រោយឆ្នាំ១៩៧៥) ដោយចេះតែមានរឿងវាយគ្នាជាមួយវៀតណាម ទើបគេឲ្យគាត់ទៅជួយមើលខាងព្រំដែនព្លៀសាន ដូចគាត់រៀបរាប់ដូចតទៅ:

"រវាងខែ១០ និងខែ១១ឆ្នាំ១៩៧៥ ដោយមានការរំលោភឈ្លានពានរបស់វៀតណាមចូលមកក្នុងខេត្តរតនៈគីរីជាបន្តបន្ទាប់ បក្សបានចាត់តាំងឲ្យខ្ញុំទៅរួមសហការណ៍ជាមួយភូមិភាគ១០៨ (ព្លៀសានចាស់) ដើម្បីរៀបចំផែនការវាយបណ្ដេញវៀតណាមឲ្យចេញពីដីយើង"។[១៦៦]

ពេលនោះលោកណីសារ៉ាន់ (ហៅយ៉ា) បានទទួលការណែនាំដូចតទៅ៖

"ពេលនោះបក្សបានលើកវិធានការនិងគោលការណ៍ពីរ:

- យកការទាក់ទងខាងផ្លូវទូត គឺការជួបចរចាដើម្បីដោះស្រាយកុំឲ្យបង្ហូរឈាមជាវិធានការសំខាន់មួយ។

- បើដោះស្រាយតាមផ្លូវទូតនេះមិនបានផល គឺវានៅតែរំលោភលើដីយើងទៀត យើងត្រូវរៀបចំវិធានការខាងផ្លូវយោធា គឺវាយបណ្ដេញវាឲ្យចេញពីទិកដីយើង។ តែបក្សណែនាំថា ទោះជាវាយខាងយោធាក៏ដោយ ក៏សំដៅទិសចំពោះវិធានការទូតខាងលើជាសំខាន់ដែរ។"[១៦៧]

[១៦៦] "ចម្លើយសារភាពរបស់មេដឹកនាំខ្មែរក្រហម" ចងក្រងដោយកាសែតសំឡេងយុវជនខ្មែរ ទំព័រ២២៥

[១៦៧] "ចម្លើយសារភាពរបស់មេដឹកនាំខ្មែរក្រហម" ចងក្រងឡើងដោយកាសែតសំឡេងយុវជនខ្មែរ ទំព័រ២២៥



ចុងខែ១១ឆ្នាំ១៩៧៥ កម្លាំងវៀតណាមក៏បានដកថយអស់ពីចំណុច "ដែលវារំលោភលើយើង" (នៅរតនៈគីរី)។

ក្រោយមកទៀត ទើបគាត់បានត្រូវចាត់តាំងជាលេខាភូមិភាគតែម្ដង។ នេះហើយដែលគាត់និយាយថា "ក្រោយមហាសន្និបាតបក្សលើកទី៤ គឺនៅដើមខែ២-៧៦ បក្សបានរៀបចំចាត់តាំងភូមិភាគព្លៀសានថ្មី (ភូមិភាគ១០៩) ដែលមាន៤ខេត្ត គឺក្រចេះ មណ្ឌលគីរី រតនៈគីរី និងស្ទឹងត្រែង។ ខ្ញុំត្រូវបានបក្សប្រគល់ភារកិច្ចឲ្យទៅទទួលជាលេខាភូមិភាគ១០៩នេះ។

ចាប់ផ្ដើមចេញដំណើរដំបូងនេះ បក្សបានណែនាំខ្ញុំឲ្យគិតគូរតែការងារព្រំដែនមួយរយៈសិនចុះ គឺខែ២-៣ ១៩៧៦។ ខាងអង្គការ ក៏បានទំនាក់ទំនងអញ្ជើញពួកយួនឲ្យចាត់តាំងប្រតិភូមួយទៅជួបចរចាជាមួយយើង នៅខាងរតនៈគីរី។

ពេលយើងជួបចរចាជាមួយពួកវានេះ គឺយើងនិយាយទាំងបញ្ហាព្រំដែននៅខាងមណ្ឌលគីរី និងខាងរតនៈគីរី ពិសេសខាងមណ្ឌលគិរី ដែលកំពុងមានការវាយគ្នាតឹងតែងខ្លាំង។ យើងថា វាចូលមកលើដីយើង ឯវាក៏ចោទថា យើងចូលទៅក្នុងដីវាដែរ ព្រោះវាប្រើផែនទីមួយដែលមានគំនូសព្រំដែនជាដីវា។ ឯយើង យើងប្រើផែនទីមួយផ្សេង ដែលមានគំនូសព្រំដែនថា ជាដីរបស់កម្ពុជា។

ចរចា ជជែកគ្នាមិនចប់។ ពេលនោះយើងក៏សម្រេចឲ្យផ្អាកការបាញ់គ្នាខាងមណ្ឌល់គីរីនេះជាបណ្ដោះអាសន្នប៉ុណ្ណឹងសិន គឺអ្នកណានៅត្រង់ណាឲ្យនៅជាបណ្ដោះអាសន្នត្រង់នោះសិន រង់ចាំការចរចា និងការដោះស្រាយរួមរបស់បក្ស និងរដ្ឋាភិបាលទាំងពីរកម្ពុជាវៀតណាមជាក្រោយ។"[១៦៨]

[១៦៨] "ចម្លើយសារភាពរបស់មេដឹកនាំខ្មែរក្រហម" ចងក្រងឡើងដោយកាសែតសំឡេងយុវជនខ្មែរ ទំព័រ២២៦

គឺខាងកម្ពុជា ដែលជាអ្នកផ្ដើមគំនិតស្នើឲ្យផ្អាកការបាញ់គ្នា អញ្ជើញខាងវៀតណាមឲ្យមកចរចាគ្នាថ្នាក់ខ្ពស់។ អាស្រ័យហេតុនេះហើយ ទើបមានការចរចាគ្នានៅភ្នំពេញ នាខែឧសភា១៩៧៦។

ប៉ុន្តែនៅក្នុងឱកាសនេះ ស្រាប់តែប្រតិភូវៀតណាមដាក់ឱសានវាទ ដូចបានជម្រាបខាងលើ។ គេទទូចទាមទារឲ្យគូសខ្សែបន្ទាត់មួយថ្មីឲ្យចំពាក់កណ្ដាលសមុទ្រនៅចន្លោះកោះត្រល់ និងកែបវិញ។ ធ្វើដូច្នេះ គឺដូចជាកាត់យកសមុទ្រ ដែលអាចបើកបរបាននៅមុខកែបនិងកំពត ព្រមទាំងសមុទ្រទឹកជ្រៅនៅខាងកើតកំពង់ផែកំពង់សោម ចេញពីកម្ពុជាហើយ។

ទី៤-ជាងមួយខែក្រោយពីឱសានវាទ ក៏មានការវាយគ្នាយ៉ាងខ្លាំងទៀត

លើបញ្ហានេះ គឺយ៉ា ជាអ្នកបញ្ជាក់។ យ៉ា បានសរសេរថា ៖

"ដល់ចុងខែ៦-៧៦ ដើមខែ៧-៧៦ មានការប៉ះទង្គិចគ្នាខ្លាំងនៅព្រំប្រទល់រវាងស្រុកស្នួលក្រចេះ...។ មានការវាយគ្នាជាប់ជាបន្តបន្ទាប់។ ពេលនោះខ្ញុំកំពុងនៅប្រជុំមជ្ឈិមខែ៧-៧៦។ បងនួន បានណែនាំខ្ញុំឲ្យសរសេរទូរលេខមួយ ប្រាប់ទៅទីកាម (គឺកម្មាភិបាលទាក់ទងរបស់វៀតណាមដែលមាននាទីទាក់ទងដោះស្រាយបញ្ហាផ្សេងៗតាមព្រំដែនជាមួយកម្ពុជា) អំពីហេតុការណ៍... ដោយស្នើឲ្យផ្អាកការវាយគ្នា ហើយស្នើឲ្យមានការជួបគ្នារវាងប្រតិភូខេត្តក្រចេះ (កម្ពុជា) និងខេត្តសុងបែ (ខាងវៀតណាម) ដើម្បីចរចា ដោះស្រាយបញ្ហាព្រំដែននេះ ជាមិត្តភាពកុំឲ្យបង្ហូរឈាម"។ តែចរចាមិនបានលទ្ធផល។

យ៉ាក៏បញ្ជាក់បន្តទៀតថា: បន្ទាប់ពីនោះមក អចិន្ត្រៃយ៍បក្សបានសម្រេចថា ឲ្យកងការពារព្រំដែនខេត្តក្រចេះដកចូលមកក្នុងដីយើងពី១៥០០ ទៅ២.០០០ ម៉ែត្រ ដើម្បីចៀសវាងការតានតឹង។

អំពីការឲ្យដកចូលនេះ អង្គការក៏បានណែនាំខាងមណ្ឌលគីរីផងដែរ ព្រោះសំណូមពរសំខាន់ ធ្វើយ៉ាងណាកុំឲ្យមានការតឹងតែងតាមព្រំដែន តែ



ក៏ត្រូវធ្វើយ៉ាងណាមិនបណ្ដោយឲ្យពួកយួន វាលុកយកដីយើងបានដែរ។[១៦៩]

ក្នុងរយៈពេលក្រោយមក តាមការអានសៀវភៅអ្នកស្រាវជ្រាវផ្សេងៗទៅ សភាពការហាក់ដូចជាស្ងប់ស្ងាត់។ ប៉ុន្តែតាមអ្នកស្រាវជ្រាវផ្សេងៗ ការវាយគ្នាហាក់ដូចជាចាប់ផ្ដើមឡើងវិញ ចាប់ពីដើមឆ្នាំ១៩៧៧។[១៧០] តើដោយមកពីអ្នកណា? ដោយខាងខ្មែរបានដកកងទ័ពឆ្ងាយពីព្រំដែនរួចហើយ មានតែមកពីខាងវៀតណាម។ គេអាចឈរលើផែនទីរបស់គេ គេអាចថា ទោះបីខ្មែរថាដកកងទ័ពឆ្ងាយពីព្រំដែនក៏ដោយ ការពិតគឺដកមិនទាន់ផុតពីដីវៀតណាមនៅឡើយទេ។

ក្រោយពីបានធ្វើសេចក្ដីថ្លែងការណ៍មួយ នៅខែធ្នូ១៩៧៦ តាមរូបភាពសេចក្ដីសម្រេចចិត្តមួយនៃប.ក.វ. អំពីការប្ដូរឃ្លោចរបស់ខ្លួន ដើម្បីការពារ និងពង្រឹងពង្រីកការទាក់ទង ពិសេសរវាងប្រជាជនវៀតណាម ប្រជាជនលាវ និងកម្ពុជា...។ នៅខែកុម្ភៈ ហាណូយក៏បានបញ្ជូនអានុរដ្ឋមន្ត្រីក្រសួងការបរទេសឈ្មោះ ហ្វាង វ៉ាន់ ឡយ មកធ្វើទស្សនកិច្ចសម្ងាត់នៅភ្នំពេញ។ គេមកស្នើសហការណ៍ជាមួយកម្ពុជាដោយបញ្ជូនជនភៀសខ្លួនខ្មែរ ដែលបានរត់ទៅវៀតណាម ហើយសុំអញ្ជើញ អ្នកដឹកនាំខ្មែរទៅប្រជុំកំពូលតណ្ដាចិនជាមួយវៀតណាម និងលាវម្ដងទៀត។ សូមរំលឹកថា ការអញ្ជើញដូចគ្នានេះបានធ្វើម្ដងរួចទៅ ហើយ សម្រាប់ប្រជុំនៅខែមិថុនា១៩៧៦។ ពេលនោះខ្មែរបានយល់ស្របជាគោលការណ៍រួចហើយ ប៉ុន្តែខ្មែរទទូចសុំឲ្យចរចាដោះស្រាយបញ្ហាព្រំដែនសិន។ ពីព្រោះបញ្ហានេះខាងប.ក.ក.បានលើកស្នើម្ដងហើយ។ កាលពីខែមិថុនា១៩៧៥ គឺតែបីខែក្រោយ ដែលប្រទេសទាំងពីរបានសន្តិភាពតែប៉ុណ្ណោះ ប្រតិភូជាន់ខ្ពស់មួយរបស់ប.ក.ក. បានទៅធ្វើទស្សនកិច្ច

---

១៦៩ "ចម្លើយសារភាពរបស់មេដឹកនាំខ្មែរក្រហម" ចងក្រងឡើងដោយកាសែតសំឡេងយុវជនខ្មែរ ទំព័រ២២៨

១៧០ ហ្វីលិព ហ្សត "ប៉ុល ពត..." ទំព័រ៣៧២

នៅហាណូយហើយបានសុំឲ្យមានកិច្ចព្រមព្រៀងមិត្តភាព និងសហប្រតិបត្តិការយូរអង្វែងមួយរវាងបក្ស និងប្រទេសទាំងពីរផង និងឲ្យរៀបចំចាប់ផ្ដើមចរចាពីបញ្ហាព្រំដែនផង។ ប៉ុន្តែខាងវៀតណាមគេចមិនព្រមពីភាក្យាលើការស្នើទាំងពីរនេះ។ តាំងពីពេលនោះមក កិច្ចព្រមព្រៀងមិត្តភាព និងសហប្រតិបត្តិការយូរអង្វែងបានត្រូវទុកមួយអន្ទើទៅហើយ ប៉ុន្តែលើការដោះស្រាយបញ្ហាព្រំដែននៅតែជាការសាកល្បងមួយសំខាន់សម្រាប់ពួកខ្មែរក្រហម ដើម្បីដឹងអំពីអាកប្បកិរិយាវៀតណាមនិងដើម្បី ដឹងថាតើការជួបប្រជុំកំពូលជាការប្រជុំរវាងអ្នកដឹកនាំនៃប្រទេសអធិបតេយ្យឬទេ។ ប៉ុន្តែការសាកល្បងនេះត្រូវបរាជ័យ ដោយសារវៀតណាមបានយកឱកាសនេះដាក់ឱសានវាទលើកម្ពុជា។ ដូច្នេះការប្រជុំកំពូល ក៏ត្រូវខកខានទៅវិញ។ ដោយសភាពការណ៍តាំងពីនោះមក មិនទាន់មានអ្វីប្រែប្រួលសោះនោះ ការអញ្ជើញលើកទីពីរឲ្យទៅប្រជុំកំពូល ក៏ត្រូវបានខាងកម្ពុជាបដិសេធម្ដងទៀត។

នៅក្នុងខែមីនា និងមេសា ការប៉ះទង្គិចគ្នាបានបន្តទៅទៀតដោយមានសំបុត្រតវ៉ាគ្នាទៅវិញទៅមកយ៉ាងជូរចត់។[១៧១] នៅថ្ងៃ៣០ ខែមេសា កម្លាំងខ្មែរក្រហមដោយមានកាំភ្លើងធំបាញ់អមផង បានចូលទៅដីវៀតណាមសម្លាប់ប្រជាជន និងកំទេចភូមិយ៉ាងចាស់ដៃ។ ខាងវៀតណាមបាននាំអ្នកសារព័ត៌មានអន្តរជាតិមកមើលដល់កន្លែងត្រៀមមតិអន្តរជាតិ ដើម្បីចូលលុកលុយកម្ពុជា។ បើប្រសិនជាសេចក្ដីថ្លែងការណ៍ខែធ្នូ១៩៧៦ មានអមទៅដោយវិធានការណ៍ជាក់ស្ដែង ដូចជាការដកកងទ័ពវៀតណាមឆ្ងាយពីព្រំដែនដូចដែលកម្ពុជាបានធ្វើមកហើយនោះ ដើម្បីជាការបន្ធូរសភាពការណ៍តានតឹងនៅព្រំដែន ដែលបានកើតមានតាំងពីវៀតណាមបានដាក់ឱសានវាទមកនោះ ប្រហែលជាព្រឹត្តិការណ៍ដែលវៀតណាមបានលើកថា ជាមូលហេតុដែលនាំឲ្យកើតមានសង្គ្រាមនោះ មិនអាចកើតមានទេ។ ដោយមិន

[១៧១] ហ៊្វីលិព ហ្សុត "ប៉ុល ពត..." ទំព័រ៣៧២



មានវិធានការណ៍របៀបនេះផងសោះ សេចក្ដីថ្លែងការណ៍ខែធ្នូ ១៩៧៦ ភ្នំពេញស្ដាប់ទៅ ហាក់ដូចជាការចោទដោយបញ្ឆិតបញ្ឆៀងមកលើខ្មែរក្រហមថា គេជាអ្នកបំផ្លាញចំណងទាក់ទងមិត្តភាពពិសេស រវាងប្រជាជនប្រទេសឥណ្ឌូចិនទាំងបីនោះទៅវិញ។ ម្យ៉ាងទៀតលោកហ្វីលិព ហ្សុត បានរកឃើញថា អំពីរឿងខ្មែរក្រហមចូលទៅវាយភូមិវៀតណាមនោះ មិនមែនកើតឡើងដោយមិនមានការបង្ករឿង ដូចការឃោសនារបស់វៀតណាមបានអះអាងនោះទេ។ ទូរលេខផ្ទៃក្នុងយោធារបស់ប.ក.ក. ដែលអាចឲ្យជឿបានពីព្រោះទូរលេខទាំងនោះមិនមែន ដើម្បីផ្សាយទេរាប់ទៅមានការប៉ះទង្គិចគ្នា ១៥លើក ដែលខ្មែរក្រហមចោទថា កើតមកពីវៀតណាមក្នុងរយៈពេលចាប់ពីថ្ងៃ១ ដល់ថ្ងៃ២៩ មេសា។[១៧២]

ម្យ៉ាងទៀតបើវៀតណាមប្ដូរផ្ដាច់ការពារ និងពង្រឹងពង្រីកការទាក់ទងពិសេស រវាងប្រជាជនវៀតណាម ប្រជាជនលាវ និងកម្ពុជា..."នោះមែនហេតុម្ដេចក៏យកការទាស់ទែងខ្វែងគំនិតគ្នាលើដី១ដុំ ២ដុំ ឬលើព្រំដែនសមុទ្រមួយក្រវិចតូចនេះ មកបង្កជារឿងឲ្យទៅជាសង្គ្រាមរវាងប្រទេសទាំងពីរទៅកើត? ដូច្នេះពិនិត្យជ្រុងណាក៏ឃើញថាបញ្ហាព្រំដែនគ្រាន់តែជាលេស ដើម្បីបង្កសង្គ្រាម ដើម្បីវៀតណាមសម្រេចមហិច្ឆិតាសហព័ន្ធឥណ្ឌូចិនរបស់ខ្លួនលើកម្ពុជា និងលាវដែរ។

ពិតមែនហើយ មុននឹងប្រើមធ្យោបាយធំ វៀតណាមបានស្នើឲ្យមានការជួបគ្នានៅថ្នាក់ខ្ពស់ ដើម្បីបញ្ចប់ឧប្បត្តិហេតុបង្ហូរឈាម។ ប៉ុន្តែបញ្ហាសំខាន់ចំពោះខ្មែរ គឺចង់ដឹងថា តើហាណូយបោះបង់ចោលយុទ្ធសាស្ត្រ "ពួសថ្វាន់រឹតកួនមាន់" របស់គេហើយឬនៅ។ តែវៀតណាមមិនគ្រាន់តែមិនព្រមដកឱសានវាទរបស់គេប៉ុណ្ណោះទេ តែនៅថ្ងៃ១២ ឧសភា១៩៧៧ វៀតណាមថែមទាំងបានប្រកាស់តំបន់សេដ្ឋកិច្ចផ្ដាច់មុខប្រវែង២០០ម៉ៃ នៅតាមឆ្នេរ

[១៧២] ហ៊្វីលិព ហ្សុត "ប៉ុល ពត..." ទំព័រ៣៧២

សមុទ្ររបស់គេធ្វើឲ្យខ្មែរ ត្រូវស្ថិតនៅចំពោះមុខការសម្រេចរបស់វៀតណាមជាការស្រេចតែម្ដង។ ដូច្នេះខាងខ្មែរក៏សុំរយៈពេលពិចារណា ហើយស្នើឲ្យមានការដកកងទ័ពពីព្រំដែនរៀងៗខ្លួន ដូចដែលគេបានធ្វើមកហើយ ក្រោយពីមានការប៉ះទង្គិចគ្នាយ៉ាងខ្លាំងនៅស្នួលរួចមក។ ប៉ុន្តែខាងវៀតណាមក៏មិនឃើញមានការឆ្លើយតបមកវិញទេ ហើយការបាញ់ផ្លោងកាំភ្លើងធំដាក់គ្នាក៏បន្តទៅទៀតពីសង្ខាងព្រំដែន ចំណែកឯប្រជាជនស៊ីវិលរាប់ម៉ឺននាក់ត្រូវជម្លៀសចេញពីតំបន់ ដើម្បីបង្ការយថាហេតុអាក្រក់បំផុត។[១៧៣]

### ទី៥-គោលជំហរកម្ពុជាប្រជាធិបតេយ្យ រហូតដល់ខែមេសា១៩៧៧

កាលបើយើងពិនិត្យមើលឲ្យហ្មត់ចត់បន្តិច យើងឃើញដូចតទៅ៖

-ចំណុចទី១ ចាប់ផ្តើមមានការប៉ះទង្គិចគ្នាភ្លាម ការណែនាំរបស់ប.ក.ក. គឺ ៖ ចរចា។ គឺជាវិធានការចម្បង។

-ចំណុចទី២ មធ្យោបាយយោធាត្រូវប្រើតែនៅពេលណាដែលការចរចាដោះស្រាយមិនបាន។ តែ...ទោះជាវាយខាងយោធាក៏ដោយ ក៏សំដៅទិសចំពោះវិធានការទូត... ជាសំខាន់ដដែល។

-ចំណុចទី៣ សូមកត់សម្គាល់ឃ្លារបស់យ៉ា... "បក្សបានណែនាំខ្ញុំឲ្យគិតគូរតែការងារព្រំដែនមួយរយៈសិនចុះ គឺខែ២-៣ ១៩៧៦"។ បានន័យថាក្នុងគំនិតរបស់អ្នកដឹកនាំខ្មែរក្រហម រឿងរ៉ាវតាមព្រំដែននេះជា រឿងឈ្លោះគ្នាតាមព្រំដែន ធម្មតាវាងថ្នាក់ក្រោមទេ អាចដោះស្រាយបានចប់សព្វគ្រប់ក្នុងរយៈតែ២ ឬ៣ខែប៉ុណ្ណោះ។

ចំណុចទី៤ វៀតណាមមិនឃើញមានគំនិតផ្តើមអ្វីទាំងអស់ ដើម្បីបន្ធូបរិយាកាស។ ឯការចរចាគ្នាខាងលើកើតមានឡើងដោយសារតែគំនិតផ្តើមរបស់ខ្មែរទេ។ ហើយវៀតណាមក៏ប្រើការចរចាសម្រាប់តែបង្កើតរឿងថែមទៀត។

[១៧៣] ហ៊្វីលិព ហ្សត "ប៉ុល ពត..." ទំព័រ៣៧៣



តាមការពិនិត្យខាងលើឃើញថា ៖

ក-រឿងរ៉ាវ ដែលបានកើតមាននៅព្រំដែនតាំងពីខែតុលា-វិច្ឆិកាឆ្នាំ១៩៧៥រហូតមក ជាការកៀបសង្កតខ្មែរខាងយោធាឲ្យទទួលឱសានវាទខែឧសភា១៩៧៦។

ខ-រឿងរ៉ាវ ដែលបានកើតមាននៅស្នួលក្នុងខេត្តក្រចេះនៅចុងខែមិថុនា ដើមខែកក្កដា១៩៧៦ ក្រោយមកទៀតក៏ជាការកៀបសង្កត់ខ្មែរខាងយោធាឲ្យទទួលឱសានវាទខែឧសភា១៩៧៦ទៀត។

ពាក្យរបស់លោកឡេ យន់ ដែលលោកនិយាយប្រាប់ទូតសូវៀតនៅថ្ងៃ១៦វិច្ឆិកាឆ្នាំ១៩៧៦នោះ ក៏បានបញ្ជាក់ទៀត។ លោកលេខាប.ក.វ.បាននិយាយថា "មិនយូរមិនឆាប់ទេប្រទេសនេះ (គឺកម្ពុជា) និងមកនៅជាមួយវៀតណាមជាពុំខាន។ ខ្មែរគ្មានផ្លូវឯណាក្រៅពីនេះទេ"។[១៧៤] តាមការកៀបសង្កត់យ៉ាងនេះ វាពិតណាស់ទៅហើយ ខ្មែរគ្មានផ្លូវឯណាក្រៅពីនេះទេ"។

ពិតមែនហើយ ប៉ុលពត មិនបានដឹងអំពីខ្លឹមសារដែលលោកឡេ យន់បានប្រាប់ទូតសូវៀតយ៉ាងណានោះទេ។ ប៉ុន្តែនៅលើដីដែលធ្លាប់មានការស្អប់ខ្ពើមគ្នាតាំងពីរាប់សតវត្សមកហើយ ឥឡូវនេះក៏មានការសាបព្រោះ ពូជពារនៃការស្អប់ខ្ពើមគ្នាសារជាថ្មីម្តងទៀត។ ខ្ញុំនៅចាំបានថា នៅពេលនោះលោកប៉ុលពតបាននិយាយអំពី "យុទ្ធសាស្ត្រ ពួសថ្លាន់រឹតកូនមាន់" គឺយុទ្ធសាស្ត្រដែលបុករុកពីក្រៅផង បំផុសចលនាប្រឆាំងពីក្នុងផង។ តទៅខាងក្រោមយើងនឹងបានដឹងកស្តុតាង នៃការដែលវៀតណាមលូកដៃចូលមកកកូរផ្ទៃក្នុង ប.ក.ក កាន់តែច្បាស់ រហូតដល់បង្កឲ្យកើតមានទំនាស់រវាងអ្នកតស៊ូខ្មែរវាយគ្នាបង្ហូរឈាមថែមទៀតផង។

[១៧៤] ស្តេហ្វិន មូរីស "ហេតុម្តេចបានជាវៀតណាមឈ្លានពានកម្ពុជា" ទំព័រ៩៦

ឥឡូវនេះអ្វីដែលលេចឡើងច្បាស់ គឺថាមិនមែនកម្ពុជាប្រជាធិបតេយ្យទេ ដែលទៅបង្ករឿងវៀតណាមដែលខ្លាំងជាងខ្លួនលើសលុបនោះ។ គឺវៀតណាមទេតើដែលយករឿងព្រំដែនធ្វើជាលេស ដើម្បីជាឱកាសដាក់បង្ខំឲ្យកម្ពុជាទទួលនៅក្រោមអាណាព្យាបាលរបស់ខ្លួន។ ពេលនេះយើងអាចយល់បានហើយថា ហេតុម្ដេចបានជាវៀតណាមគេចមិនព្រមទទួលសន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការណ៍យូរអង្វែងមួយរវាងប្រទេស និងប្រជាជនទាំងពីរកម្ពុជា-វៀតណាម ហើយមិនព្រមឲ្យមានការចចាលើបញ្ហាព្រំដែនដូចដែលគណៈប្រតិភូជាន់ខ្ពស់ប.ក.ក.បានស្នើកាលពីខែមិថុនា ១៩៧៥។[១៧៥] គឺមកពីវៀតណាមមិនព្រមទទួលស្គាល់ ប.ក.ក។ តែបែរជាមកដាក់ឱសានវាទលើកម្ពុជា ដើម្បីសង្កត់កម្ពុជាឲ្យទៅប្រជុំកំពូលឥណ្ឌូចិន។ គឺមកពីគេចង់បានសន្ធិសញ្ញា ដូចដែលគេបានធ្វើជាមួយលាវនៅខែកក្កដាឆ្នាំ១៩៧៧ បើកសិទ្ធិឲ្យវៀតណាមមានកងទ័ពរបស់ខ្លួនលើទឹកដីលាវ ដើម្បី "ប្រយុទ្ធប្រឆាំងនឹងគ្រប់ផែនការនិងសកម្មភាពវិទ្ធង្សនា.. របស់កម្លាំងប្រតិកិរិយាបរទេស"។ ពាក្យនេះជាពាក្យសំដៅប្រទេសផ្សេងៗនៅក្នុងតំបន់ផង និងទៅចិនប្រជាមានិតផង។

[១៧៥] ខៀវ សំផន "ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់" ទំព័រ៧៩



## ដើមរឿងដែលនាំឲ្យក្លាយទៅជាមានការកាប់សម្លាប់?

ចំពោះបញ្ហានេះ ខ្ញុំអាចឆ្លើយបានតែខ្លះៗនៅឡើយទេ។ ប៉ុន្តែខ្ញុំយល់ថា ការរកឃើញរបស់ខ្ញុំពិតមែនតែមិនទាន់ពេញលេញអាចមានប្រយោជន៍ដែរ ក្នុងន័យថា វាអាចជាតម្រុយដើម្បីបើកឲ្យមានការស្រាវជ្រាវបានវែងឆ្ងាយថែមទៀត ដោយឈរលើការដែលអ្នកស្រាវជ្រាវពីមុនមកបានរកឃើញច្រើនណាស់មកហើយ តែចាំបាច់ត្រូវស្រាវជ្រាវឲ្យបានសព្វានុមត្តិកុំឲ្យទោទន់ទៅតាមការលំអៀង ឬទៅតាមការស្អប់ ឬការខឹងសម្បារ។

**ទី១-អំពីព្រឹត្តិការណ៍ដ៏ចម្លែកៗមួយចំនួន ដែលបានកើតមានឡើងនៅក្នុងប្រទេសពីខែកុម្ភៈ ដល់ខែមេសាឆ្នាំ១៩៧៦**

ថ្ងៃ២៥កុម្ភៈ ១៩៧៦ មានការផ្ទុះធ្វើឲ្យរំជួយទីក្រុងសៀមរាប។ រហូតដល់ថ្ងៃនេះ គ្មានអ្នកណាអាចនិយាយបានច្បាស់ថា មកពីមូលហេតុអ្វីទេ។

បន្តមកទៀត មានរឿងមួយទៀតដែលគ្មានអ្នកណានឹកស្មានដល់សោះ។

នៅចុងខែមីនា រឿងអាស្រូវមួយទាក់ទិន្នដល់កម្មាភិបាលថ្នាក់ខ្ពស់ម្នាក់ឈ្មោះកុយ ធួន បានឮដល់ប៉ុលពត។ ជាទូទៅគេធ្លាប់ដឹងថាសាម៉ីខ្លួនមានចំណុចខ្សោយជាមួយស្រីៗ។ ដើម្បីជាការកំសាន្តរបស់គាត់ គាត់បានចាត់តាំងក្រុមសិល្បៈមួយថែមទៀតផង។ ដូច្នេះមានការប៉ះពាល់ដល់ឥទ្ធិពលដឹកនាំរបស់គាត់ច្រើនហើយ។

អាស្រ័យហេតុនេះហើយ បានជាគណៈអចិន្ត្រៃយ៍ បានដកគាត់ពីតំណែងលេខាភូមិភាគឧត្តរ ឲ្យមកធ្វើជារដ្ឋមន្ត្រីពាណិជ្ជកម្មវិញ ដែលមិនទាក់ទងដល់ការអប់រំដឹកនាំប្រជាជនផ្ទាល់។ ដូច្នេះមិនសំខាន់ដល់តំណែងមុនទេ។ ប៉ុន្តែគាត់នៅតែបន្តធ្វើដូចមុនទៀត។ គាត់រៀបចំឲ្យនារីដែលធ្លាប់ជាកំណាន់របស់គាត់ពីមុនមក ការជាមួយយុទ្ធជនម្នាក់ឈ្មោះឡុង។ នេះជា

វិធីសម្រាប់គាត់ផ្ដាច់ ឡុង ពីនារីម្នាក់ទៀតដែលគាត់ពេញចិត្ត។ យុទ្ធជននោះខឹងខ្លាំង ក៏ផ្សព្វផ្សាយរឿងនេះពាសពេញ។ កុយ ធួន (ហៅធុច) ដឹងក៏ប្រើឲ្យគេសម្លាប់ឡុងចោលទៅ។

ចំពោះ ប៉ុលពត រឿងផ្ទុះនៅសៀមរាបពីថ្ងៃ២៥ ខែកុម្ភៈ ជារឿងមួយធំហើយ ពិសេសជាងពីរខែមកហើយ រកដំណើរដើមទងមិនទាន់ឃើញទៀត។ ម្យ៉ាងទៀតកុយ ធួនប្រព្រឹត្តយ៉ាងនេះ បង្ហាញថា គាត់មិនមែនជាអ្នកដិវត្តិន៍ត្រឹមត្រូវទេ ពិសេសចំពោះកម្មាភិបាលថ្នាក់ខ្ពស់។ ចេញពីគំនិតនេះទៅនាំឲ្យភ្ជាប់ទៅព្រឹត្តការណ៍នៅសៀមរាប។ សៀមរាបពីមុនធ្លាប់នៅក្រោមការគ្រប់គ្រងរបស់គាត់ពីមុនមក ដោយមានសុទ្ធជាសហការីជិតស្និតមួយធ្វើការជាមួយគ្នា។ ដូច្នេះចោទបញ្ហាសួរថា តើការដែលគាត់ត្រូវដកពីតំណែងលេខាភូមិភាគឧត្តរ នេះអាចធ្វើឲ្យគាត់ទំនាស់រហូតដល់ធ្វើសកម្មភាពបំផ្លាញបដិវត្តន៍វិញទេ? ក្នុងសភាពដែលមិនទាន់ច្បាស់លាស់ និងដើម្បីបង្ការគ្រប់យថាហេតុ គាត់ក៏ត្រូវតម្រូវឲ្យមកនៅមួយកន្លែង នៅផ្ទះមួយក្រោមការតាមដានរបស់គណៈអចិន្ត្រៃយ៍។

ប៉ុន្តែ៦ថ្ងៃមុនការឃាត់ខ្លួនកុយធួននេះ ក៏កើតមានព្រឹត្តិការណ៍ចម្លែកមួយទៀត។ ព្រលឹមស្រាង១ថ្ងៃ២ មេសា គ្រាប់បែកដៃមួយគ្រាប់ផ្ទុះនៅក្រោយវាំង។ យុទ្ធជនដែលគេសង្ស័យថា ជាអ្នកគប់ឆ្លើយថា គេធ្វើតាមបញ្ជារបស់កម្មាភិបាលយោធា២នាក់នៃកងពល១៧០របស់ភូមភាគបូព៌ា ដែលទើបតែផ្ទេរមកឲ្យសេនាធិការកណ្ដាល ហើយដែលបោះទីតាំងនៅខាងកើតឃាងខាងត្បូងភ្នំពេញ ចាប់ពីច្បារអំពៅមកតាមស្ពានមុនីវង្ស មហាវិថីនរោត្តមព្រះរាជវាំង និងវត្តភ្នំ។ កម្មាភិបាលយោធាទាំងពីរនាក់នោះ ក៏ឆ្លើយដាក់អតីតបញ្ជាការកងពល១៧០នេះ ឈ្មោះចាន់ ចក្រី និងកម្មាភិបាលសំខាន់ម្នាក់ទៀតនៃភូមិភាគបូពោឈ្មោះឈូក ដែលជាលេខាតំបន់២៤ ស្រុកកំពង់ត្របែក។[១៧៦]

[១៧៦] រឿងរ៉ាវដែលខ្ញុំរៀបរាប់នៅក្នុងវគ្គនេះ ខ្ញុំផ្អែកលើសៀវភៅលោក ហ្វីលិព ហ្សូត ទំព័រ ៣៥៤ និង ៣៥៥។



### ទី២-ការចាប់កម្មាភិបាលថ្នាក់ខ្ពស់ជាលើកដំបូង

ជុំវិញការទំលាក់គ្រាប់បែកនៅសៀមរាប លោកបែន គៀរណាន់ បានសរុបឃើញថាមានមតិ៤។ វិទ្យុកម្ពុជាប្រជាធិបតេយ្យបានចោទភ្លាមៗទៅលើយន្តហោះអាមេរិកធុនអែហ្វ១១១។ លោកស្ទីវហ៊ិ ដែរ សង្ស័យយន្តហោះធុនអែហ្វ៥របស់ថៃ។ លោកហ្សុន ម៉ាកបែតហ៍ គិតដល់យន្តហោះមីករបស់វៀតណាម តែក្រោយមកគាត់ទទួលស្គាល់ថា អាចជាមីករបស់ភ្នំពេញក៏សឹងតែមាន។

លោកបែន គៀរណាន់ ហាក់ដូចជាលំអៀងមកជឿលទ្ធភាពចុងក្រោយនេះ។ គាត់ផ្អែកលើពាក្យបញ្ជាការកងអានុសេនាធំម្នាក់នៅក្នុងតំបន់សៀមរាបដែលបានរត់ទៅថៃកាលពីឆ្នាំ១៩៧៧ ហើយថា មួយថ្ងៃមុនការទម្លាក់គ្រាប់បែកនេះ លោកប៉ា ថុល (ហៅសុទ្ធ)លេខាតំបន់១០៦ (សៀមរាប) បានប្រជុំ "កម្មាភិបាលកុម្មុយនីស្តនៅក្នុងតំបន់យ៉ាងតិច៣០នាក់"។ ថានៅក្នុងអង្គប្រជុំនេះ យុទ្ធជនទាំងអស់ចង់បះបោរដើម្បីទាំងអស់គ្នា បានត្រឡប់ទៅផ្ទះវិញហើយធ្វើការដូចមុនពេលដណ្ដើមយកភ្នំពេញបាន..."។ លោករហូតដល់អះអាងថា លោកកុយ ធួន ក៏ចូលរួមប្រជុំពេលនោះផងដែរ។ លោកចោទសួរថា "តើអាចខាងមជ្ឈឹមដឹងអំពីការប្រជុំនេះ ហើយប៉ុនប៉ងទម្លាក់គ្រាប់បែកលើពួកបះបោរឬទេ? លោកបែន គៀរណាន់ជឿថា៖ "លទ្ធភាពនេះក៏អាចមានដូចលទ្ធភាពផ្សេងទៀតទាំងអស់។"[១៧៧] បើយើងពិនិត្យតាមការដែលលោកសុទ្ធ និងអ្នកដែលបានរួមជាមួយគាត់នៅរក្សាតំណែងនៅតំបន់១០៦ អស់ពេញមួយឆ្នាំក្រោយមកទៀត ក៏បង្អុលថាពេលនោះខាងមជ្ឈឹមមិនទាន់ដឹងរឿងនៅឡើយទេ។ ពេលក្រោយយូរមកហើយទេទើបដឹង។ ដូច្នេះហើយបានជា៩ខែក្រោយមកហើយទេ ទើបគេសម្រេចបញ្ជូនលោកកុយ ធួនទៅស២១ គឺនៅថ្ងៃ១៥ មករា ហើយគេចាប់អ្នកដែលនៅក្រោមបង្គាប់គាត់ ដូចជា

[១៧៧] បែន គៀរណាន់ "របបប៉ុល ពត" ទំព័រ៣១៧

លោក សុទ្ធ និងលោក ស្រេង (ដែលពេលនោះធ្វើជាអានុលេខាភូមិភាគឧត្តរ)។ ចំពោះលោកចក្រី និងលោកឈូកវិញ គេមិនឃើញមានការរុញរាពីសំណាក់អ្នកដឹកនាំខ្មែរក្រហមដូចក្នុងករណីលោកកុយ ធួនទេ។ សេចក្ដីសារភាពកម្មាភិបាលយោធាទាំងពីរនាក់នៃកងពល១៧០អាចស្រប និង អ្វីដែលលោកប៉ុលពតសង្ស័យយូរមកហើយចំពោះកម្មាភិបាលទាំងពីរនាក់នេះ ព្រមទាំងកម្មាភិបាលប៉ូពាមួយចំនួនទៀតៗ ។ ដោយឡែកតែលោកចក្រី តាំងពីមួយរយៈមកហើយ ប៉ុលពតមិនសូវទុកចិត្តទេ។ ឧទាហរណ៍នៅពេលប្រជុំគណៈអចិន្ត្រៃយ៍ ថ្ងៃ៩ តុលា១ ៩៧៥ លោកបានកត់សម្គាល់ថា ទោះបីកងពលរបស់គាត់ "ខ្លាំង" ក៏ដោយ តែការអប់រំនយោបាយដល់យុទ្ធជនមិន "សូវជ្រៅទេ" ហើយចក្រីខ្លួនឯងក៏ "ថ្មី" មានតួនាទីក៏ដោយសារ "វៀតណាម"។ "យើងត្រូវតាមដានឲ្យជាប់បន្តិច"។[១៧៨] ខ្ញុំយល់ឃើញថា លោកប៉ុលពត មានប្រសាសន៍យ៉ាងនេះនៅចំពោះមុខគណៈអចិន្ត្រៃយ៍ គឺលោកមានប្រសាសន៍ដោយទទួលខុសត្រូវ មិនមែននិយាយតាមការស្អប់លោក ចក្រី ដោយរឿងអ្វីនោះទេ។ គឺលោកមានប្រសាសន៍ក្នុងឋានៈជាលេខាបក្ស ដែលតាមដានលោក ចក្រី ជាយូរណាស់មកហើយ។ ឯលោក ឈូក ក៏លោកអាចបានតាមដានជាយូរមកហើយដែរ។

ការចាប់កម្មាភិបាលថ្នាក់ខ្ពស់ពីរនាក់ខាងបូព៌ានេះហើយ ដែលនាំឲ្យមានការបោសសំអាតផ្ទៃក្នុងពីមួយទៅមួយជាប់រដឹក ពិសេសពួកអតីតឥស្សរៈដែលបានសហការជាមួយពួកវៀតមិញកាលពីសម័យសង្គ្រាម៩ឆ្នាំ (១៩៤៥-១៩៥៤) រហូតដល់ពីរឆ្នាំក្រោយមកលោក សូ ភឹម ត្រូវបាញ់សម្លាប់ខ្លួនឯង។ ហេតុម្ដេចបានជាការបោសសំអាតប៉ះពាល់កម្មាភិបាល ដែលជាអតីតឥស្សរៈដែលបានសហការណ៍ជាមួយពួកវៀតមិញ កាលពីសម័យសង្គ្រាម៩ឆ្នាំមុនគេ? តទៅនេះយើងនឹងខិតខំរកចម្លើយទៅនឹងសំនួរនេះ។

[១៧៨] បែន គៀរណាន់ "របបប៉ុល ពត" ទំព័រ១០១



### ទី៣- អំពីវិធីដែលប៉ុលពតប្រើឯកសារដែលបានមកពីការធ្វើទារុណកម្ម

ខ្ញុំលំអៀងទៅយល់ស្របតាមអ្នកនិពន្ធឈ្មោះហ្វីលិព ហ្សរត ដែលគាត់សរសេរថា ប៉ុលពត មិនមែនល្ងង់ខ្លៅរហូតដល់ជឿលើឯកសារ ដែលបានមកពីការធ្វើទារុណកម្មនោះទេ។[១៧៩] ប៉ុន្តែលោកហ្វីលិព ហ្សរត ហាក់ដូចជានិយាយហួសបន្តិចហើយដែលគាត់ថា តួនាទីនៃ (គុក) ស២១ និងសេចក្ដីសារភាពដែលវាផ្ដល់ឲ្យនោះ មិនមែនសម្រាប់ផ្ដល់ព័ត៌មានទេ គឺសម្រាប់តែផ្ដល់ភស្ដុតាងនៃ "អំពើក្បត់" ដែលក្រុមដឹកនាំត្រូវការ ដើម្បីចាប់អ្នកដែលគេបានសម្រេចរួចទៅហើយថាត្រូវចាប់នោះ។ តាមខ្ញុំធ្លាប់យល់ របៀបរបបធ្វើការរបស់លោក ប៉ុលពត លើបញ្ហាអ្វីក៏ដោយ ក៏គាត់ត្រូវតែប្រមូលឯកសារឲ្យបានច្រើនជាអតិបរិមាយកមកវិភាគ ទើបគាត់សម្រេចៗ ខ្ញុំធ្លាប់យល់ ពីព្រោះគាត់ថែមទាំងបានចងក្រងជាឯកសារក្រោមចំណងជើងថា "របៀបរបបដឹកនាំ និង ធ្វើការងារតាមគោលការណ៍វិភាគ ៣-៧-៨ សម្រាប់អប់រំយុទ្ធជន និង កម្មាភិបាលគ្រប់ថ្នាក់"។[១៨០] ផ្ទាល់ខ្លួនគាត់ ក៏អនុវត្តគោលណ៍នេះជាប់ៗ ឧទាហរណ៍កាលពីគាត់ស្ថិតនៅជាចំណាប់ខ្មាំងរបស់វៀតណាមកាលពីឆ្នាំ ១៩៦៣ ដោយគាត់បានអនុវត្ត គោលការណ៍នេះហើយទើបគាត់អាចតាមដានសភាពការណ៍ ហើយវិភាគឃើញផែនការអាមេរិករៀបចំ ប្រើលោក លន់នល់ ឬ លោក សឺង ង៉ុកថាញ់ឲ្យធ្វើអ្វីមួយ ប្រឆាំង និង សម្ដេច នរោត្តម សីហនុ។ វិភាគឃើញយ៉ាងនេះហើយ ទើបលោកកោះប្រជុំមជ្ឈឹមយកសេចក្ដីសម្រេចចិត្ត ធ្វើការតស៊ូអាវុធរួមផ្សំនយោបាយ។ គឺសេចក្ដីសម្រេចចិត្តនេះហើយដែលលោកបែនគៀរ ណាន់ហៅថា "ពាក្យរបស់ប៉ុលពត" ដែលបានជួយកម្មាភិបាលជាច្រើនឲ្យរត់ចូលព្រៃទាន់ពេលវេលា ដើម្បីគេអាចដឹកនាំការតស៊ូ អាវុធរួមផ្សំនយោបាយពីក្នុងព្រៃមកវិញ និងដើម្បីគេអាចដឹកនាំ

[១៧៩] ហ្វីលិព ហ្សត "ប៉ុល ពត..." ទំព័រ៣៥៨

[១៨០] សូមអានឧបសម្ព័ន្ធទី៣

ការតស៊ូអាវុធបានចាប់ពីដើមឆ្នាំ១៩៦៨ទៅ។ លោកប៉ុលពត ជាអ្នកដឹកនាំមួយនាក់ ដែលយកចិត្តទុកដាក់តាមដានកម្មាភិបាលជាទីបំផុត ពិសេសកម្មាភិបាលសំខាន់ៗ ដើម្បីក្តាប់បានចំណុចខ្លាំងចំណុចខ្សោយរបស់គេ ហើយអប់រំកសាងគេឲ្យចំផង ដើម្បីដឹងអ្នកណាល្អ អ្នកណាមិនល្អផង។ ដូច្នេះតាមលំនាំនេះ យើងអាចសន្និដ្ឋានបានថាក្នុងរឿងលោកចក្រី និង កម្មាភិបាលប៉ូញ ក៏ដូចកម្មាភិបាលផ្សេងទៀត ដែលមានគេឆ្លើយដាក់លោកមិនជឿតែលើឯកសារ ជាចម្លើយដែលបានមកពីការធ្វើទារុណកម្មនោះទេ។ "សេចក្តីសារភាពគ្រាន់តែជាឯកសារមួយក្នុងចំណោមឯកសារផ្សេងទៀត ដែលគាត់ធ្លាប់បានតាមដានជាហូរហែមកហើយតែប៉ុណ្ណោះ។

ឧទាហរណ៍ជាក់ស្តែងដែលបង្ហាញថា លោកប៉ុលពតមិនចេះតែចាប់ពាសវាលពាសកាលមានច្រើនៗ សុំជូន១ចំនួនដូចតទៅ:

ពិតមែនតែលោកកុយធួនត្រូវបានឃាត់ខ្លួនតាំងពីខែមេសាឆ្នាំ១៩៧៦ គឺមុនលោកចក្រី លោកឈូក និងលោកយ៉ាក៏ដោយ តែដល់ទៅថ្ងៃ ១៥ មករា ១៩៧៧ គឺ៩ខែក្រោយមក ទើបគណៈអចិន្ត្រៃយ៍បញ្ជូន គាត់ទៅស២១ ដើម្បីសួរចម្លើយ។ នេះគឺមក ពីមុនតំបូងបង្អស់ លោកប៉ុលពតមិនមានសង្ស័យអ្វីទៅលើលោកកុយធួនផងទេ។ លោកដឹងថាលោកកុយធួនមិនស្អាតចត់ទេ ទាំងក្នុងការងារទាំងក្នុងសិលធ៌មរស់នៅ។ ឯរឿងដែលនាំឲ្យលោកបានត្រូវដកចេញពីតួនាទីជាលេខាភូមិភាគ គឺដោយសារតែលោក បាត់ឥទ្ធិពលដឹកនាំក្នុងចំណោមប្រជាជននៅមូលដ្ឋាន តែលោកក៏ត្រូវបានតែងតាំងឲ្យធ្វើរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។ ក្រោយមកលោកត្រូវបានឃាត់ខ្លួនដោយសារតែគាត់សម្លាប់យុទ្ធជនឈ្មោះឡុង ដើម្បីបំបាត់ដានរឿងសីលធ៌មរបស់គាត់តែប៉ុណ្ណោះ។ ប៉ុន្តែលោកប៉ុលពតឲ្យសារៈសំខាន់ទៅលើរឿងរបស់លោកចក្រី លោកឈូក លោកយ៉ា ជាង ប្រហែលជាមកពីលោកប៉ុលពតបានតាមដានយូរមកហើយ ហើយមានរឿងធ្ងន់ធ្ងរជាងនេះទៅទៀត។



ក្រៅពីឧទាហរណ៍ ដូចបានជម្រាបមកហើយនេះ មានឧទាហរណ៍មួយចំនួនទៀតដែលបញ្ជាក់ថាប៉ុលពតមិនចេះតែជឿតាមសេចក្តីសារភាពទេ។ គឺដូចជាករណីលោកស្រីមឿន ប្រពន្ធលោកពេជជាងដែលជាឯកអគ្គរដ្ឋទូតកម្ពុជាប្រជាធិបតេយ្យប្រចាំប៉េកាំង។ មានចម្លើយឆ្លើយដាក់លោកស្រីដល់ទៅ ៨ដងថាគាត់ជាខ្សែរបស់លោកកុយធួន។ ប៉ុន្តែ លោកប៉ុល ពតថា "បើមឿនក្បត់អ្នកផ្សេងទៀតក៏ក្បត់អស់ហើយ"។ ចំណែកឯលោកសូភឹមវិញ មានចម្លើយឆ្លើយដាក់គាត់ដល់ទៅជាង ១២ដង។[១៨១] ក្នុងនេះមានចម្លើយរបស់លោកយ៉ាចុះថ្ងៃ២៩ កញ្ញា ១៩៧៦ ថាគាត់ជាមេលើលោកទៅទៀតតែគ្រាន់តែមិនចេញចំហ។[១៨២] ក្នុងចម្លើយនេះលោកយ៉ាបានរៀបរាប់ពិស្តារដែរអំពីការទាក់ទង រវាងអ្នកទាំងពីរនាក់នេះ។ លោកយ៉ាថាលោកតែងឆ្លៀតឱកាស ពេលប្រជុំជាផ្លូវការដូចជាសន្និបាត ឬប្រជុំមជ្ឈឹម៦ខែម្តង ដើម្បីទៅលេងកន្ទែងដែលលោកសូភឹមសម្រាក (គេរៀបចំគ្រែជូនសមាជិកអចិន្ត្រៃយ៍ចាស់ទាំង៣នាក់ សម្រាកដាច់ដោយឡែកពីគេ) ហើយនិយាយគ្នាពីការងារសម្ងាត់របស់គេ។ លោកយ៉ាថា គាត់ចាប់ផ្តើមធ្វើដូច្នេះតាំងពីមហាសន្និបាតខែកក្កដា ឆ្នាំ១៩៧១នៅភូមិភាគឧត្តរម៉េះ។ ពេលខ្លះគេទាំងពីរនាក់ធ្វើជានិយាយពីខ្លឹមសារដែលនៅក្នុងរបៀបវារៈម្តងៗ ដើម្បីបង្ការក្រែងមានអ្នកណាមកជិតស្តាប់ទៅឮថាគេមិននិយាយអ្វីក្រៅពីការងារទេ។ តាមសេចក្តី សារភាពនេះ លោកយ៉ាថាលោកសូភិមឧស្សាហ៍ដាស់តឿនឲ្យគាត់ខំយកចិត្តទុកដាក់កសាងកម្មាភិបាលជនជាតិ នៅឦសាន ពីព្រោះភូមិភាគនេះមានសារៈសំខាន់ណាស់សម្រាប់បក្សថ្មី។ លោកយ៉ាថា "បងភិមមានប្រសាន៍តិចៗថាបញ្ហាវៀតណាម វាមិនមែនជាបញ្ហាកំបុត ចប់គឺចប់នោះទេ។ បញ្ហានេះជាបញ្ហាយូរអង្វែង វែងឆ្ងាយណាស់។

[១៨១] ហ្វីលិព ហ្សត "ប៉ុល ពត..." ទំព័រ៣៥៨

[១៨២] "ចម្លើយសារភាពរបស់មេដឹកនាំខ្មែរក្រហម" ចងក្រងឡើងដោយកាសែតសំឡេងយុវជនខ្មែរទំព័រ ២២៨ដល់២៣៥

បន្តមកទៀតនៅខែតុលាឆ្នាំ១៩៧៥ ពេលប្រជុំមជ្ឈឹមវិសាមញ្ញដើម្បីជម្រុញចលនាវាយសម្រុក ផ្តាច់ព្រ័ត្ររំដោះភ្នំពេញ លោកយ៉ាថា "បងភឹមមានមតិថា ៖

បើករណីទី១ យើងឈ្នះមុនវៀតណាម វៀតណាមនឹងចូលមិនចុះមកកម្ពុជាទេ។ កិច្ចដំណើរការរបស យើងជួបការលំ បាកស្មុគស្មាញហើយ។

បើករណីទី២ វៀតណាមឈ្នះមុនវិញ នោះវៀតណាមវានិងចូលមកកម្ពុជាដូចទឹកបាក់ទំនប់ ហើយវានិងខ្លាំងជាង ក្រោយរដ្ឋប្រហារ១៩៧០ ទៅទៀត។ ក្នុងករណីនេះ ដំណើរការរបស់យើង ច្បាស់ជាស្រួលហើយ ព្រោះមានវៀតណាមជាបង្អែក។

លោកយ៉ាថាបងភិមបន្តទៀតថា ៖ "តាមពិនិត្យសភាពការណ៍ករណីទី២មានលទ្ធភាពស្រួលជាង ព្រោះហេតុផលឃើញសព្វគ្រប់អស់ហើយ។ ករណីទី១ មានដែរតែតិចណាស់"។

បញ្ហាដែលចោទសួរគឺថា មានសេចក្តីសារភាពយ៉ាងនេះហើយហេតុម្តេចបានជាលោកប៉ុលពតមិនមានវិធានការចំពោះលោកសូភិមភ្លាមនោះ? ហើយទុកឲ្យលោកសូភិមនៅមានសេរីភាពរហូតដល់ខែឧសភា ១៩៧៨ គឺជិត២ឆ្នាំក្រោយមកទៀត។ ប្រហែលមកពីលោកប៉ុលពតយល់ឃើញថាហួរហែមក ទោះបី លោកសូភឹមបានបង្ហាញនូវគោលជំហរពឹងផ្អែកលើវៀតណាមក៏ដោយលោកសូភឹមក៏បានបង្ហាញនូវការគោរពតាមហេតុផលរបស់លោកជាបន្តបន្ទាប់វិញដែរ។ ដូច្នេះគាត់ខ្លាចក្រែងលោកយ៉ាមានបំណងចង់បំផ្លាញប.ក.ក. ចេះតែឆ្លើយបន្ថែមបន្ថយដាក់កម្មាភិបាលល្អ នាំឲ្យមានការចាប់ខុស។ ឬមួយគាត់គិតថាបើមានវិធានការចំពោះបុគ្គលលោកសូភិមភ្លាម តែក្បាលម៉ាស៊ីនដឹកនាំនៅបូព៌ា នៅទាំងដុល ខ្លាចបុគ្គលណាដែលជាអានុរបស់លាកសូភិម ធ្វើអបគមន៍យកភូមិភាគបូព៌ា (ជូនណាថែមទាំងឮសានទៅជាមួយថែមទៀតបានមួយផ្ទាំង ខាងកើតទន្លេមេកុង) ទៅភ្ជាប់



ជាមួយវៀតណាមតែម្តង។ ដូច្នេះគាត់មានវិធីកាត់ដៃកាត់ជើងលោកសូភឹមសិន។ រួចហើយទើបដល់ ដើមឆ្នាំ១៩៧៨គាត់បែរមករកចាប់លោកសូភឹមវិញ...។

តាមមើលបញ្ហានេះ គ្មាននរណាអាចឆ្លើយបានទេ។ សំណូមពររបស់ខ្ញុំគ្រាន់តែចង់បង្ហាញថាពីផ្នែកខាងគាត់លោក ប៉ុលពត មានការប្រយត្ន័ប្រយែងណាស់ក្នុងការប្រើប្រាស់ចម្លើយសារភាពនោះ។ ប៉ុន្តែក៏មិនមានន័យថាលោកចាប់ចង់សុទ្ធតែត្រូវនោះទេ។

ទី៤- អំពីការជ្រៀតជ្រែករបស់ពួកកុម្មុយនីស្តវៀតណាមក្នុងកិច្ចការផ្ទៃក្នុងរបស់ ប.ក.ក. ជាបន្តបន្ទាប់

កាលពីឆ្នាំ១៩៧៣-៧៤ ភ្នាក់ងាររដ្ឋការនៃក្រសួងការបរទេសអាមេរិកម្នាក់ឈ្មោះកេណិតគ្វីន បានស្រាវជ្រាវឃើញថា នៅផ្ទៃក្នុងចលនាបះបោរមានការបែងចែកគ្នាជាពួករឹង (ខ្មែរក្រហម) និង "ពួកមជ្ឈម" "លំអៀងសីហនុ" "លំអៀងវៀតណាម" (ខ្មែររំដោះ)។[១៨៣] លោកកេណិតគ្វីនអះអាងថា "នៅព្រៃវែងពួកខ្មែររំដោះត្រួតត្រាចលនាខ្មែរកុម្មុយនីស្ត"។

ចំណែកឯលោកហ្វីលិព ហ្សូតវិញ លោកបានផ្តល់ភស្តុតាងច្បាស់ថាការពិតគឺវៀតណាមជាអ្នកបង្កើតកងទ័ពខ្មែរ រំដោះនេះឡើង។ គាត់បានសរសេរដូចតទៅ៖ "តាមទ្រឹស្តី លោក (សម្តេច សីហនុ) ដឹកនាំពួកខ្មែររំដោះដែលខុសពីអង្គភាពខ្មែរក្រហមត្រង់គេពាក់ព្រះឆ័យាលក្ខណ៍របស់ព្រះអង្គនៅលើឯកសណ្ឋានរបស់គេ។ ប៉ុន្តែកងទ័ពទាំងនោះ ការពិតគឺ វៀតណាមជាអ្នកបង្កើតសោះ។ ដូចដែលសម្តេចបានកត់សម្គាល់យ៉ាងជូរចត់ លោកមិនដែលឃើញមានខ្សែចាត់តាំងបញ្ជាការ ពីក្រោមមកដល់រណៈសិរ្សរួបរួមជាតិកម្ពុជានៅប៉េកាំងទាល់តែសោះ។ កងទ័ពសីហនុនិយមទទួលបញ្ជាពី

---

[១៨៣] បែន គៀរណាន់ "របបប៉ុល ពត" ទំព័រ៦៥

ហាណូយទៅវិញ”។[១៨៤] ដូច្នេះ លោកហ្វីលិព ហ្សតបានផ្តល់ភស្តុតាង ច្បាស់ថា វៀតណាមបានលូកដៃយ៉ាងជ្រៅចូលជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងប.ក.ក. តាំងពីមុនឆ្នាំ ១៩៧៣ម៉្លេះ គឺឆ្នាំដែលលោក កេណេតគ្វីនបានរកឃើញថា “នៅផ្ទៃក្នុងចលនាបះបោរ មានការបែងចែកគ្នាជាពួករឹង (ខ្មែរក្រហម) និង “ពួកមធ្យម” “លំអៀងសីហនុ” “លំអៀងវៀតណាម” (ខ្មែររំដោះ)”។

តើពួកកុម្មុយនីស្តវៀតណាមបានលូកដៃចូលជ្រៀតជ្រែកកិច្ចការផ្ទៃក្នុង ប.ក.ក.តាំងពីពេលណាមក?

យើងបានដឹងហើយថា មេៗដឹកនាំខ្មែរក្រហមបានចាត់ទុកថាការបះបោររបស់កសិករនៅសំឡូត បានចាប់ផ្តើមឡើងរហ័សពេកទោលតែមួយកន្លែងដូច្នេះងាយស្រួលឲ្យគេកម្ទេច។ ប.ក.ក.ក៏បានរកវិធីបញ្ចប់ការបះបោរនេះដើម្បីដកឃ្លាយកពេលរៀបចំ ដើម្បីងើបឡើងតស៊ូវិញឲ្យបានស្រុះគ្នាទូទាំងប្រទេស។

វេលាត្រូវបានកំណត់នៅដើមខែមករាឆ្នាំ១៩៦៨។ ចលនាបានប្រព្រឹត្តទៅស្រុះគ្នាល្អគួរសមដែរ។ ប៉ុន្តែខាងបូព៌ាអត់បានចូលរួមនឹងគេទេ។ លោកបែន គៀរណាន់ បានសរសេរថា “នេះហើយជាសញ្ញានៃការបាក់បែកផ្ទៃក្នុងប.ក.ក។ នៅទីបញ្ចប់ ៨ខែក្រោយ ទើបផ្នែកខាងបូព៌ារបស់សូភឹមមកចូលរួមការផ្ទុះអាវុធ គឺនៅខែសីហា១៩៦៨។ ហើយលោកគ្រាន់តែធ្វើសកម្មភាពយោធាបន្តិចបន្តួចប៉ុណ្ណោះ។ ផ្នែកដឹកនាំនៃប.ក.ក ត្រូវមកទាក់ទងនិយាយពន្យល់ “យ៉ាងប៉ិនប្រសប់បំផុត” (ពាក្យនេះជាពាក្យរបស់លោកបែន គៀរណាន់) ទើបភូមិភាគបូព៌ាយល់ស្របចូលរួមផ្ទុះអាវុធតាមវិធីដូចជម្រាបពីខាងលើនេះ។[១៨៥]

[១៨៤] ហ្វីលិព ហ្សត “ប៉ុល ពត...” ទំព័រ២៤០ (អ្នកនិពន្ធយោងទៅព្រះរាជនិពន្ធរបស់សម្តេចក្រោមចំណងជើងថា “សង្គ្រាម និង សេចក្តីសង្ឃឹម” បោះពុម្ពនៅរោងពុម្ព ហាហ្សែត ប៉ារីស ទំព័រ១៥)

[១៨៥] បែន គៀរណាន់ “តើ ប៉ុល ពត ឡើងមកកាន់អំណាចតាមវិធីណា?” ទំព័រ២៥០



យើងបានឃើញហើយថា លោកសូភឹម និងលោកវន វេត មានការគិតគូរច្រើន ទាក់ទងដល់យុទ្ធសាស្ត្រតស៊ូអាវុធនេះ។ ប៉ុន្តែមិនយូរប៉ុន្មានទេក៏ឯកភាពគ្នាវិញដោយពេលនោះ “ជាទូទៅ... កម្លាំងខាងផ្នែកយោធា និងខាងផ្នែកសន្តិសុខ (របស់លោកលន់ នល់) អាចធ្វើអ្វីក៏បាន ដោយឯករាជ្យពីសម្តេចសីហនុ ឬដោយមានការគាំទ្រដោយមិនចេញស្តីពីព្រះអង្គ ហើយពេលនោះ-គ្រប់ប្រភពទាំងអស់មូលមតិគ្នាលើចំណុចនេះ ការរាតត្បាតបានក្លាយទៅជាក្រិតក្រមជាទូទៅហើយ”។[១៨៦] ចុះហេតុម្តេចបានជាដល់ថ្ងៃកំណត់ លោកសូភឹមប្រែប្រួលនៅពេលចុងក្រោយវិញទៀត? ខ្ញុំយល់ឃើញថាចំពោះសំណួរនេះ យើងអាចយោងទៅលើពាក្យរបស់លោកបែន គៀរណាន់ដែលគាត់ថា “ដែល (លោកសូភឹម) ខុសប្លែកពីខាងដឹកនាំរួម គឺគាត់នៅតែបន្តការទាក់ទងយ៉ាងជិតស្និតជាមួយពួកកុម្មុយនីស្តវៀតណាម” ទោះបីលោកបែន គៀរណាន់ចង់មិនចង់ក៏ដោយ លោកបានផ្តល់ចម្លើយចំពោះសំណួរនេះ។[១៨៧]

ឯការទាក់ទងជិតស្និតនេះ តាមការអានសៀវភៅរបស់លោកបែនគៀរណាន់ដដែលនេះ គឺកម្មាភិបាលសំខាន់ៗខាងបូព៌ាដោយរួមទាំងលោកសូភឹមផងនៅតែបន្តទៅជ្រកនៅក្នុងមូលដ្ឋានរបស់ពួកវៀតកុង នៅក្នុងទឹកដីវៀតណាមខាងត្បូង ដូចកាលពីជំនាន់តស៊ូនយោបាយមក។[១៨៨] បើផ្គុំព័ត៌មានដែលលោកបែន គៀរណាន់បានរកឃើញនេះទៅនឹងព័ត៌មាន ដែលលោកកេណេតគ្វីនអំពីខ្មែរក្រហម ខ្មែររំដោះ រួមទាំងភស្តុតាងដែលលោកហ្វីលិព ហ្សតបញ្ជាក់ថា វៀតណាមជាអ្នកបង្កើតកងទ័ពខ្មែររំដោះទៅ នាំឲ្យឃើញច្បាស់គួរសមដែរថា ការដែលនាំឲ្យលោកសូភឹមខកខានមិនបានចូលរួមផ្ទុះអាវុធតាមថ្ងៃកំណត់ គឺមកពីលោកបានទទួលឥទ្ធិពលពីវៀតណាម។

[១៨៦] បែន គៀរណាន់ “តើ ប៉ុល ពត ឡើងមកកាន់អំណាចតាមវិធីណា?” ទំព័រ២៣១

[១៨៧] បែន គៀរណាន់ “តើ ប៉ុល ពត ឡើងមកកាន់អំណាចតាមវិធីណា?” ទំព័រ២៥០

[១៨៨] បែន គៀរណាន់ “តើ ប៉ុល ពត ឡើងមកកាន់អំណាចតាមវិធីណា?” ទំព័រ២៨២

លើបញ្ហាផ្ទៃក្នុងបក្សខ្មែរនេះអ្នកផងបានដឹងអស់ហើយអំពីដើមកំណើតនៃបក្សខ្មែរដែលចេញមកពីផ្នែកពីរដែលមានលក្ខណៈខុសគ្នាឆ្ងាយ។ ផ្នែកទីមួយគឺដូចដែលយើងបានឃើញក្នុងជំពូកទី៣ហើយ ជាពួកឥស្សរៈចាស់ដែលវៀតណាមបានប្រមែប្រមូលពីនេះផងពីនោះផង ហើយលើកឡើងដើម្បីបិតបាំង សកម្មភាពរបស់គេនៅស្រុកខ្មែរកាលពីអំឡុងឆ្នាំ ១៩៤៦-១៩៥៤។ ផ្នែកទី២ ជាញាណជនដែលបានទៅរៀនសូត្រនៅប្រទេសបារាំង គ្រូបង្រៀន សិស្ស និស្សិត និង អ្នករដ្ឋការ។ ដូចយើងបានឃើញពីខាងលើហើយ ក្រោយឆ្នាំ ១៩៥៤ ក្រោយពីកម្លាំងវៀតមិញដកចេញពីស្រុកខ្មែរទៅហាណូយ និង ដោយមានការរាតត្បាតពីរដ្ឋអំណាចព្រះមហាក្សត្រនរោត្តមសីហនុ ព្រមទាំងស៊ីវហេងក៏ក្បត់ទៀត ផ្នែកជនបទនៃចលនា ក៏ធ្លាក់ក្នុងសភាព តក់ស្លុត រួញក្តោប ហើយសម្ងំសុខៗ ដូច្នេះគឺផ្នែកទីក្រុងដែលចិញ្ចឹមចលនាឲ្យនៅរស់បាន ហើយតាមរយៈនេះ ក៏កាន់ចង្កូតដឹកនាំចលនា។

ប៉ុន្តែ នៅពេលតស៊ូអាវុធគឺពួកឥស្សរៈចាស់ដូចជា រស់ញឹម កែពក សូភឹម ម៉ុក ប្រាសិទ្ធ ជាអ្នកដឹកនាំការប្រយុទ្ធផ្ទាល់នៅនឹងកន្លែង។ ពួកបញ្ញាជនដឹកនាំប្រយុទ្ធផ្ទាល់តែនៅព្រៃសានទេ។

លោកហ្វីលិព ហ្សូតបានសរសេរថា ៖ "ដោយសម្លឹងមើលទៅអនាគតវែងឆ្ងាយ ស យល់ឃើញថា ចាំបាច់ដោយខានមិនបានទេផ្នែកទាំងពីរនេះត្រូវតែរួបរួមគ្នា។ ប៉ុន្តែដើម្បីបង្រួបបង្រួមកម្លាំងទាំងពីរដែលខុសពីគ្នាយ៉ាងនេះឲ្យទៅជាសាច់មួយជាមួយគ្នាក្នុងបក្សតែមួយជាការលំបាក"។ អ្នកនិពន្ធសរសេរទៀតថា ៖ "នៅឆ្នាំ១៩៦៨ និង ១៩៦៩ ការចាំបាច់ដឹកនាំ "សង្គ្រាមប្រជាជន" ប្រឆាំងនឹងសត្រូវដែលខ្លាំងជាងខ្លួនលើសលុប ការចាំបាច់ទប់ទល់ការរាតត្បាត ដែលស្រោចមកលើផ្នែកទីក្រុង ក៏ដូចផ្នែកជនបទ ជំនឿថា ទៅអានាគត ចលនាកុម្មុយនិស្តនិងក្លាយទៅជាចលនាមួយខ្លាំង ហើយសេចក្តីសង្ឃឹមថាផលនៃជ័យជម្នះ និងត្រូវបានចែកគ្នាស្មើៗគ្នាបង្កើតបានជាមូលដ្ឋានមួយសម្រាប់គេរួបរួមគ្នា។ ដូច្នេះជាលើកដំបូងហើយដែលលេចចេញឡើង



នូវចលនាបដិវត្តន៍ជាតិមួយពិតប្រាកដ។ ប៉ុន្តែការផ្សាំមែកឈើទាំងពីរនេះ នៅតែមិនបានរលាយជាសាច់មួយជាមួយគ្នាបានល្អនៅឡើយ។ សម្ព័ន្ធភាពមួយដែលជៀសមិនផុត ប៉ុន្តែដែលផ្ទុយពីធម្មជាតិនៅបន្តទៅទៀតបានដោយសារតែការខិតខំអស់ពីកម្លាំងកាយចិត្ត និង ដោយ "ប៉ិនប្រសប់បំផុត" របស់ ស និងសហការីរបស់គាត់។[១៨៥] បញ្ហោចាទសួរថាតើមកពីមូលហេតុអ្វីបានជាការផ្សាំមែកឈើទាំងពីរនៃចលនាខ្មែរក្រហម នៅតែមិនបានរលាយជាសាច់មួយជាមួយគ្នាបានល្អសោះយ៉ាងនេះ? យើងពិនិត្យឃើញថា ៖

១ - ដូចលោកហ្វីលិព ហ្សូតបានសរសេរដូច្នេះថា ៖ "អ្វីៗដែលបានកើតឡើងនៅពាក់កណ្តាល ខែមេសា ១៩៧៥ ជាលទ្ធផលនៃនយោបាយដែលបានចាប់ផ្តើមបដិសន្ធិតាំងពីជំនាន់ឆ្នាំ៦០ ហើយដែលមានឫសគល់ជាពេលវេលាឆ្ងាយជាងនេះទៅទៀត (អ្នកនិពន្ធចង់ចង្អុលទៅជំនាន់វៀតមិញចូលធ្វើសកម្មភាពនៅស្រុកខ្មែរពីឆ្នាំ១៩៤៦-១៩៥៤)។ រឿងនេះមិនមានអ្វីជាការចៃដន្យទេ។ ប្រធានភូមិភាគទាំងប្រាំមួយ -រស់ញឹម និង គង់ សុផល នៃភូមិភាគពាយ័ព្យ ពក នៃភូមិភាគឧត្តរ ណីសារ៉ាន់ នៃភូមិភាគព្រៃសាន សូភឹមនៃភូមិភាគបូ៌ព ម៉ុកនៃភូមិភាគនិរតី បានចាប់ផ្តើមជីវិតតស៊ូរបស់គេក្រោមទង់ឥស្សរៈក្នុងសង្គ្រាមប្រឆាំងបារាំង"។

គេបានបង្ហាញដូចៗគ្នានូវភាពចចេស ងងិតងល់មើលអ្វីឃើញតែមួយជ្រុងៗ នូវភាពឃោរឃៅ និង ការមើលងាយជីវិតមនុស្ស ដូចពួកឥស្សរៈជំនាន់៣០ឆ្នាំមុននេះ។ នៅក្នុងរដ្ឋកុម្មុយនីស្តជាទូទៅការសម្រេចអ្វីទាំងអស់សុទ្ធតែធ្វើឡើងនៅក្នុងក្របខ័ណ្ឌថ្នាក់ដឹកនាំកណ្តាល ហើយការអនុវត្តសេចក្តីសម្រេចនេះត្រូវតែធ្វើឡើងឲ្យបានដូចគ្នាដូចជាមនុស្សម្នាក់។ ស្រុកខ្មែររបស់ខ្មែរក្រហមគ្មានវិន័យទេ។ ...គេគោរពតាមការណែនាំរបស់គណៈមជ្ឈឹម នៃប.ក.ក តែ

[១៨៥] ហ្វីលិព ហ្សូត "ប៉ុល ពត..." ទំព័រ១៧៩ (សូមកត់សម្គាល់ថាលោកបែនគៀរណាន់ក៏បានប្រើពាក្យ "ប៉ិនប្រសប់បំផុត" នេះរួចមកហើយនៅពេលដែលលោកនិយាយអំពីខាងដឹកនាំកណ្តាលពន្យល់លោកសូភឹមឱ្យចូលរួមក្នុងចលនាតស៊ូអាវុធ)

ភូមិភាគនីមួយៗធ្វើតាមការយល់ដឹងរបស់គេរៀងៗខ្លួន... ហើយការពិតទាំងនេះដែលមាននៅថ្នាក់ភាគក៏មានដូចគ្នានៅថ្នាក់ក្រោមតៗទៅទៀត...។[១៥០]

២- វៀតណាមនៅតែបន្តចិញ្ចឹមឥទ្ធិពលរបស់គេលើពួកឥស្សរៈទាំងនេះ ដោយវាយប្រហារមាគ៌ា "ឯករាជ្យ-អធិបតេយ្យជាប់រហូតរៀងមក រហូតដល់មិនព្រមទទួលស្គាល់ថាឆ្នាំ១៩៦០ ជាឆ្នាំកំណើតរបស់ ប.ក.ក ថែមទៀតផង។ គេនៅតែទទូចទាមទារយកឆ្នាំ១៩៥១ ជាឆ្នាំកំណើតរបស់បក្សកម្ពុជា ទោះបីបក្សនេះរលាយអស់ទាំងស្រុងទៅហើយតាំងពីឆ្នាំ១៩៥៤ ដែលកម្លាំងវៀតមិញត្រូវដកពីកម្ពុជាទៅវៀតណាមវិញនោះហើយក៏ដោយ។

៣- ដោយអំពើជ្រៀតជ្រែកជាក់ស្តែងពីវៀតណាមដូចយើងបានឃើញជាបន្តបន្ទាប់រួចមកហើយពីខាងលើនេះៗ នៅឱកាសនេះ យើងសុំធ្វើការសង្កេតបន្តិចចុះ ៖ ភស្តុតាងលោកហ្វីលិព ហ្សតបានផ្តល់ឲ្យអំពីវៀតណាមជាអ្នកបង្កើតចលនាខ្មែររំដោះ រួមនិងភស្តុតាងដែលអ្នកស្រាវជ្រាវផ្សេងទៀតបានរកឃើញថែមទៀតនោះ បានបញ្ជាក់ថាការតាមដានទាំងប៉ុន្មានរបស់លោកប៉ុលពត ចំពោះចក្រី ឈូក យ៉ា និងអតីតកម្មាភិបាល ដែលបានរួមជាមួយពួកវៀតមិញ តាមគោលការ ៣-៧-៨ របស់លោកគឺត្រូវៗ ដូច្នេះមិនមែនដូចលោកហ្វីលិព ហ្សតសរសេរថា "តួនាទីរបស់គុក ស២១ និងសេចក្តីសារភាពមិនមែនសម្រាប់ផ្តល់ព័ត៌មានជាសំខាន់នោះទេ គឺសម្រាប់តែផ្តល់ "ភស្តុតាង" នៃអំពើក្បត់ដែលគេត្រូវការ ដើម្បីចាប់អ្នកណាដែលគេសម្រេចចាប់រួចទៅហើយនោះទេ"។ នយោបាយឯករាជ្យពីវៀតណាមតម្រូវឲ្យអនុវត្តនយោបាយដាច់ខាតនៅក្នុងប្រទេស ពីព្រោះបើមិនពឹងលើវៀតណាមទេ មានតែបែរមករកពឹងលើកសិករៗ ដូច្នេះត្រូវហ្វឹកហ្វឺន និង លត់ដំកសិករក្នុងការតស៊ូលំបាកវេទនា ទាំងការតស៊ូជាតិទាំងការតស៊ូវណ្ណៈដោយឯករាជ្យម្ចាស់ការខ្លួនទីពឹងខ្លួន ដោយមិនខ្លាចពលិកម្មអ្វីទាំងអស់ៗ ផ្ទុយទៅវិញ បើ

[១៥០] ហ្វីលិព ហ្សត "ប៉ុល ពត..." ទំព័រ២៨១



មិនពឹងលើកសិករទេ គឺគេចមិន ផុតពីត្រូវរណបបរទេសទេ។ ចំពោះប៉ុលពត ការតស៊ូជាតិជាប់ និងការតស៊ូរបស់កសិករបេះមិនដាច់ទេ។ ប៉ុន្តែកសាងកម្លាំងកសិករដោយផ្អែកលើកម្មាភិបាលសក្តិភូមិជាការលំបាកបំផុត។

## ទី៤-ការបង្ហើបរបស់នាយទាហានថ្នាក់ខ្ពស់វៀតណាមម្នាក់ នៅឆ្នាំ១៩៧៣

ក្នុង "សេចក្តីសារភាព" របស់គាត់ លោកយ៉ា បាននិយាយពីនាយទាហានជាន់ខ្ពស់វៀតណាមម្នាក់ ដែលមកពីហាណូយជាមួយក្រុមជូនដំណើរសម្តេចនរោត្តមសីហនុ នៅពេលដែលព្រះអង្គយាងមកធ្វើទស្សនកិច្ចតំបន់រំដោះកាលពីឆ្នាំ១៩៧៣ថា នាយទាហានវៀតណាមរូបនោះបានមកជួបគាត់ ហើយស្នើជួយពួកគាត់ឲ្យកសាងកម្លាំងដោយឡែក។

លោកយ៉ា[១៥១] បានរៀបរាប់ដូចតទៅ: "ចំពោះបង (វាចង្អុលខ្ញុំ) បើមានត្រូវការអ្វីដោយឡែកឲ្យទំនាក់ទំនង និងភូមិភាគរបស់វាដែលនៅជាប់គ្នានោះចុះ។ វាដឹងថា ខ្ញុំនៅវៀសានកាលនោះ។ វាថាតើខ្ញុំមានដែលបានជួបសមមិត្តមិញ និងហ្វាងនៅខ្លង់រាបបេញរបស់វាហើយឬនៅ? ខ្ញុំថាមិនដែលបានជួបទេ។ វាប្រាប់ថា មានការអីឲ្យជួបទៅ គេនឹងជួយឲ្យអស់លទ្ធភាព។ គឺវានិយាយឲ្យទំនាក់ទំនងឲ្យវាជួយកសាងកម្លាំងដោយឡែក។ ខ្ញុំថាខ្ញុំមិនទាន់ត្រូវការទេ។ វាថាគ្រាន់តែបង្ការមុនដល់ពេលមានការរកភ្លាមបានភ្លាម។" ពេលនោះលោកយ៉ាបានបដិសេធថា គាត់មិនបានទទួលការស្នើជួយពីសំណាក់នាយទាហានជាន់ខ្ពស់វៀតណាមនោះទេ។ ប៉ុន្តែចំពោះប៉ុលពតវិញ គាត់បានឃើញសេចក្តីសារភាពរបស់លោក ឈូក និងសេចក្តីសារភាពផ្សេងទៀតដែលទាក់ទងដល់លោកយ៉ារួចហើយ។ ម្យ៉ាងទៀតសេចក្តីសារភាពរបស់យ៉ានេះអាចនាំឲ្យគាត់ថា នាយទាហានវៀតណាមជាន់ខ្ពស់ ដែលមកដល់ពីហាណូយភ្លាម តម្រង់ទៅរកលោកយ៉ាភ្លាម ក៏បានដឹងពីតួនាទីរបស់លោក

[១៥១] ចម្លើយលោកយ៉ា ចុះថ្ងៃ២៩កញ្ញា១៩៧៦ "ចម្លើយសារភាពរបស់មេដឹកនាំខ្មែរក្រហម" ចងក្រងឡើងដោយកាសែតសំឡេងយុវជនខ្មែរទំព័រ២២៨ ដល់២៣៥

យ៉ាច្បាស់អស់ហើយ។ អ្វីដែលគេបាននិយាយជាមួយលោកយ៉ា គឺជាការពាំនាំមតិណែនាំពីគណៈដឹកនាំរបស់ប.ក.វ. មកបក្សប្រជាជនកម្ពុជា។ ហើយលោកប៉ុលពត ក៏អាចគិតទៀតថា ដូច្នេះអាចមានការទាក់ទងជាប់រវាងប.ក.វ. ជាមួយពួកអតីតឥស្សរៈជំនាន់ "សង្គ្រាម៩ឆ្នាំ" តាមរយៈកម្មាភិបាលស្នូលមួយចំនួនរបៀបដូចជាលោកយ៉ានេះ ដោយរំលងលើ និងដោយសម្ងាត់ពី ប.ក.ក ជាបន្តបន្ទាប់មកហើយ យ៉ាងហោចណាស់ក៏ចាប់ពីពេលដែលវៀតណាមដឹងថា ប.ក.ក ឈប់ទទួលការណែនាំពីប.ក.វ គឺក្រោយពីផ្ទុះចលនាតស៊ូអាវុធពីឆ្នាំ១៩៦៨មកម្ល៉េះ។ ដូច្នេះការបង្ហើបរបស់នាយទាហានថ្នាក់ខ្ពស់វៀតណាមនេះគ្រាន់តែជាការបញ្ជាក់ថា វៀតណាមមានបំណងកំចាត់គាត់ និងរំលាយ ប.ក.ក. តាំងពីឆ្នាំ១៩៦៨នោះមកម្ល៉េះ។ វៀតណាមទម្លាក់កំហុសអំពីការលំបាករបស់គេកាលពីឆ្នាំ១៩៦៨-១៩៧០ ដែលគេត្រូវខ្ទេចខ្ទីកម្លាំងអស់ជាច្រើន ទៅលើការដែលតាមគេយល់លោកសាឡុតសមិនព្រមស្តាប់គេ ហើយធ្វើការតស៊ូអាវុធនាំឲ្យសម្តេចនរោត្តម សីហនុធ្លាក់ទៅក្នុងការហ៊ុមព័ទ្ធរបស់លន់ នល់ និងអាមេរិក។ ការពិតដូចយើងបានឃើញពីខាងលើមកហើយសម្តេច នរោត្តម សីហនុត្រូវបានកម្លាំងខាងស្តាំរបស់លោកលន់ នល់ហ៊ុមព័ទ្ធតាំងពីខែកញ្ញាឆ្នាំ១៩៦៦មកម្ល៉េះ គឺនៅពេលដែលលោកឧត្តមសេនីយ៍ លន់ នល់ បានត្រូវចាត់តាំងជានាយករដ្ឋមន្ត្រីដោយសភាដែលចេញមកពីការបោះឆ្នោតនៅឆ្នាំនោះម្ល៉េះ។ តែលោកឡេ យន់ និង អ្នកដឹកនាំវៀតណាមមិនយល់សភាពការណ៍កម្ពុជា ក៏យល់ថាគឺជាបច្ច័យនៃការងើបឡើងតស៊ូអាវុធរបស់ខ្មែរក្រហម កាលពីដើមឆ្នាំ១៩៦៨ ទៅវិញ។ ប៉ុន្តែបើប្រសិនជាមិនមានខ្មែរក្រហមធ្វើការតស៊ូ ដោយឯករាជ្យម្ចាស់ការទល់នឹងកម្លាំងពាតព្វាតរបស់កងទ័ពលោក លន់ នល់ ទេ នៅពេលរដ្ឋប្រហារនឹងត្រូវលោក លន់ នល់ កំទេចដូចបក្សកុម្មុនិស្ត ឥណ្ឌូនេស៊ី ហើយពេលនោះមិនអាចមានរណសិរ្ស រួមរួមជាតិកម្ពុជាទេ ឯវៀតណាមវិញក៏នឹងត្រូវអាមេរិក លន់ នល់ រដ្ឋការវៀតណាមខាងត្បូងវ៉ៃផ្ទប់ពីខាងលិចកម្ពុជាផង



ពីខាងកើតកម្ពុជាផង។ ពេលនោះជាការពិបាកប៉ាន់ស្មានណាស់ថា តើសភាពការណ៍នឹងទៅជាយ៉ាងណាទៅវិញនោះ។

វៀតណាមក្នុងឋានៈគេជាប្រទេសធំ គេមិនបានគិតដល់យថាហេតុនេះទេ គេមើលឃើញតែលោក សាឡុតស និង ប.ក.ក មិនព្រមស្តាប់បង្គាប់គេ ហើយគេចាត់ទុកគាត់ថា មិនមែនជាសម្ព័ន្ធមិត្តមួយជាទីគាប់ចិត្តតែប៉ុណ្ណោះ។ ដូច្នេះ វៀតណាមមិនត្រូវការគាត់ និង ប.ក.កទេ។ ប៉ុន្តែ រហូតដល់ថ្ងៃនេះ វៀតណាមធ្វើអ្វីគាត់មិនបានតែប៉ុណ្ណោះ។ នេះជាការបញ្ជាក់លើកទីមួយ។

ការជួបរបស់គាត់ជាមួយលោក ឡេ យន់ នាចុងឆ្នាំ១៩៦៩ នេះ ជាការបញ្ជាក់លើកទីពីរ។

**ទី៦ - តើក្នុងចម្លើយសារភាពរបស់លោក កុយធួន ហៅធុចមានខ្លឹមសារអ្វីដែលអាចនាំឲ្យលោកប៉ុលពតយកចិត្តទុកដាក់?**

ចម្លើយនេះចុះថ្ងៃ៤ ខែមីនា ឆ្នាំ១៩៧៧។[១៥២] តាមខ្ញុំយល់ ក្នុងចម្លើយនេះមានខ្លឹមសារសំខាន់បីដែលអាចនាំឲ្យលោកប៉ុលពត យកចិត្តទុកដាក់។

១- សេចក្តីសារភាពនេះអាចនាំឲ្យលោកប៉ុលពតកាន់តែមានជំនឿថា លោកចាប់លោកយ៉ាមិនខុសទេ។ ហើយលោកយ៉ាអាចជាបុគ្គលមួយមានតួនាទីសំខាន់ក្នុងបក្សថ្មីដែលគេកំពុងរៀបចំ។

២- តែបញ្ហាដែលលោកប៉ុលពតអាចចាប់អារម្មណ៍ជាងអ្វីៗទាំងអស់ទាក់ទង និង សេចក្តីសារភាពរបស់លោកកុយធួននេះគឺរឿងដែលលោកខឿនប្រធានមន្ទីរ៨៧០យកការសម្ងាត់របស់គណៈអចិន្ត្រៃយ៍គឺរឿងលោកវី និង លោកឡៅ ជាលេខា និង អនុលេខារតនគិរីរាយការណ៍ទៅលោកយ៉ា។ រឿងនេះក្រៅពីលោកខឿន គ្មាននរណាដឹងទេ។ ដូច្នេះ នេះហើយ

[១៥២] "ចម្លើយសារភាពរបស់មេដឹកនាំខ្មែរក្រហម" ចងក្រងឡើងដោយកាសែតសំឡេងយុវជនខ្មែរទំព័រ១០៦ ដល់១១៥

ដែលអាចនាំឲ្យលោកប៉ុលពតយល់ថា លោកខៀនរាយការណ៍ប្រាប់បក្សពួកគាត់ ក្នុងពេលប្រជុំរវាងអ្នក៣នាក់ នៅចុងខែ១២-៧៥មែន ទើបលោកយ៉ា និង លោកកុយធួនដឹង។ បានជាលោកខៀនរាយការណ៍ ពីព្រោះលោក វ៉ី និង លោកឡៅនេះជា "កម្មាភិបាលទទួលខុសត្រូវភូមិភាគឦសាន" របស់បក្សថ្មី។ លោកខៀនបានរាយការណ៍ប្រាប់លោកយ៉ាថា "បើទុកឲ្យសមមិត្ត វ៉ី សមមិត្តឡៅ ធ្វើសកម្មភាពបែបនេះតទៅទៀត មិនល្អទេ ព្រោះខ្ញុំដឹងថាអង្គការចាប់អារម្មណ៍ណាស់ពីការដែលសមមិត្តទាំងពីរ អនុវត្តមាគ៌ាខុសបំភ្លៃមាគ៌ានេះវាច្បាស់ក្រឡែតពេក។ ...តាំងពីដើមមក អង្គការយកចិត្តទុកដាក់ណាស់រឿងសាមគ្គីជនជាតិនេះ"។ លោកខៀនបន្ថែមថា៖ រឿងនេះបើមិនដោះស្រាយឲ្យរហ័សទេ មុខតែនិងនាំឲ្យយើងខូចខាតកម្លាំងហើយ"។ រឿងនេះហើយ ដែលនាំឲ្យលោកយ៉ាអញ្ជើញលោកធុចមកប្រជុំពិភាក្សាគ្នានៅចុងខែ១២ ឆ្នាំ១៩៧៥។ ឯសកម្មភាពរបស់ "សមមិត្តវ៉ី" និង "សមមិត្តឡៅ" នោះ គឺលោកយ៉ាក៏ទទួលស្គាល់ដែរថា "សមមិត្តវ៉ី និង សមមិត្តឡៅ និងកម្មាភិបាលមួយចំនួនទៀត បានធ្វើការចោទប្រកាន់ដល់កម្មាភិបាលខាងក្រោមមួយចំនួន ដល់ប្រជាជនមួយចំនួនថាសុទ្ធតែពួក "ក្បត់" ហើយក៏មានផែនការចាប់ ។ ខ្លះចាប់បានក៏សម្លាប់ចោល ខ្លះទៀតក៏នាំគ្នារត់ជាមួយ និងបងប្អូនឯទៀតចូលទៅដែនដីវៀតណាម ដែនដីលាវ អស់រាប់សិប រាប់រយគ្រួសារ"។ ក្រោយអ្នកទាំង៣នាក់ប្រជុំគ្នាយ៉ាងនេះ នៅចុងខែ១២-៧៥ ហើយនៅវេលាយប់មួយខែ១-៧៦ លោកប៉ុលពតក៏អញ្ជើញអ្នកទាំង៣នាក់មកពិភាក្សាគ្នា។ លោកចង់ផ្លាស់សមមិត្តទាំងពីរឲ្យទៅនៅខាងកសិកម្មវិញ ហើយរកកម្មាភិបាលថ្មីទៅជំនួស។... ពេលនោះលោកប៉ុលពតមិនទាន់ចាត់ទុកសកម្មភាពរបស់លោក វ៉ី និង លោកឡៅថាជាការបំផ្លើសមាគ៌ាទេ។ លោកអាចគិតថា អ្នកទាំងពីរជាជនជាតិ ដូច្នេះហើយគេមិនទាន់យល់មាគ៌ា។

៣- នៅផ្នែកខាងចុងនៃសេចក្ដីសារភាពរបស់លោក កុយ ធួន នេះ លោកថា លោកយ៉ាបានសង្កត់អំពីសារៈសំខាន់នៃភូមិភាគឦសាន ដែល



មានព្រំប្រទល់ជាប់នឹង លាវ និង វៀតណាមដែលជា "មិត្តស្លាប់រស់ជាមួយយើង" "សន្យាជួយយើងគ្រប់ពេលវេលាទាំងអស់"។ ប៉ុលពតក៏អាចយល់ថាអំពីលោកយ៉ាថាលោកបានប្រកែកមិនព្រមទទួលការស្នើរបស់នាយទាហានជាន់ខ្ពស់វៀតណាមនោះជាការមិនពិតទេ។ ការពិតអាចមានការទាក់ទងគ្នាជាប់ជាមួយវៀតណាម យ៉ាងហោចណាស់ ក៏តាំងពីឆ្នាំ១៩៧៣នោះមកហើយ។

ម្យ៉ាងទៀតលោកប៉ុលពតអាចយល់ថា គឺមកពីលោកយ៉ានិយាយយ៉ាងនេះហើយ បានជាគាត់អូសទាញកម្មាភិបាលបញ្ញាជនដែលមានទំនាស់ និងនយោបាយរបស់លោកបាន។ ធម្មតាអ្នកទាំងនេះមិនទទួលការដឹកនាំរបស់កម្មាភិបាល ដូចជាលោកយ៉ានេះ និង កម្មាភិបាលដែលចេញមកពីពួកវៀតមិញទេ។

សូមបញ្ជាក់ថា មុននេះលោកខៀនជាកម្មាភិបាលវ័យក្មេងជាទីសង្ឃឹមបំផុតរបស់ប៉ុលពតពីព្រោះ លោកខៀនជាកូនចៅអ្នកស្រែទាប់ក្រោម តែបានរៀនសូត្រចេះដឹងល្មមគួរសម (គាត់បានចូលរៀនអានុវិទ្យាល័យព្រះសីហនុនៅកំពង់ចាម) ដើម្បីយល់ដឹងទ្រឹស្ដីបដិវត្តន៍បានជ្រៅជ្រះទៅមុខទៀត ថែមទាំងមាន ពិសោធន៍អំពីការងារក្នុងមូលដ្ឋានច្រើនមកហើយ។[១៩៣]

[១៩៣] ត្រង់នេះខ្ញុំសុំបើកវង់ក្រចកបន្តិច៖ មានមតិខ្លះថា ក្រោយពីលោកខៀនបានត្រូវចាប់ទៅ គឺខ្ញុំត្រូវឡើងធ្វើជាប្រធានមន្ទីរ៨៧០ជំនួស។ ការពិត មិនមែនដូច្នេះទេ។ ខ្ញុំមិនដឹងជាគណៈអចិន្ត្រៃយ៍តែងតាំងអ្នកណាជំនួសលោកខៀននោះទេ។ ដូចជម្រាបស្រាប់ហើយពេលនោះ លក្ខការណ៍សម្ងាត់ម៉ឺងម៉ាត់ណាស់។ សូម្បីតែនៅក្នុងអង្គភាពតែមួយដូចមន្ទីរ៨៧០នេះ ក៏នៅតែលក្ខការណ៍សម្ងាត់។ សូម្បីតែលោកខៀនធ្វើអ្វី ទៅណាមកណាក៏ខ្ញុំមិនត្រូវចង់ដឹងចង់ឮអ្វីផងទេ។ ជាហូរហែរមកគាត់មិនសូវនៅមន្ទីរទេ។ ប្រពន្ធខ្ញុំកាន់ជើងក្រានបាយ ទុកម្ហូបនៅលើតុបាយជូនគាត់ៗ ជាញឹកញយណាស់មិនឃើញគាត់មកហូបទេ។ យូរៗទៅហាក់ដូចជាស៊ាំនិងសភាពការណ៍នេះ។ លោកខៀនទៅណាមកណាក៏មិនបានជាគិត។ ដូច្នេះទាំងប្រពន្ធខ្ញុំ ទាំងខ្ញុំមិនដឹងថា គេចាប់គាត់ផងទេ។ ដូច្នេះគេតែងតាំងអ្នកណាជំនួស ក៏រឹតតែមិនបានជាគិតទៅទៀត។ ជូនណាអស់ពីលោកខៀនទៅ គេប្រើកម្មាភិបាលម្នាក់ទៀត ឈ្មោះប៉ង់ (ឈ្មោះដើម ឈឹម សំអោក) ដែលជាកម្មាភិបាលជាទីទុកចិត្តបំផុតរបស់លោកប៉ុល ពត តាំងពីរយៈកាលមន្ទីរ១០០មកម៉្លេះ។ ក្នុងការដាក់ស្ដែងពេល

*ទី៧- ហេតុម្តេចបានជាទំហំនៃការចាប់ចងនិង នៃការស្លាប់ធំយ៉ាងនេះ?*

*តាមយោបល់ខ្ញុំ មូលហេតុមានច្រើន ហើយជះបច្ច័យលើគ្នាទៅវិញទៅមកនាំឲ្យរដ្ឋអំណាចដ៏ក្មេងខ្ចីត្រូវប្រឈមមុខនឹងសភាពការណ៍លំបាក សែនលំបាក។*

*១-គួរញ្ញាក់ថា លោកប៉ុលពតបានរួមជាមួយគណៈអចិន្ត្រៃយ៍ចាប់តែកម្មាភិបាលសំខាន់ៗនៅក្នុងបក្សទេ។ ហើយលើបញ្ហានេះលោកមានការប្រយត្ន័ប្រយ៉ែងជាទីបំផុត ពីព្រោះលោកជ្រាបច្បាស់ថា ទំរាំកសាងកម្មាភិបាលបានម្នាក់ៗត្រូវលត់ដំកម្មាភិបាលនោះក្នុងចលនាប្រយុទ្ធដ៏តឹងតែង ស្មុគស្មាញស្លាប់រស់ សារចុះសារឡើងយូរណាស់។ ដូច្នេះកម្មាភិបាលដែលត្រូវចាប់នោះមានចំនួនតិចទេ ប្រហែលមិនហួសពីប៉ុន្មានរយនាក់ទេ។*

*ប៉ុន្តែដោយម្នាក់ៗ ដែលត្រូវចាប់ជាកម្មាភិបាលទទួលខុសត្រូវកាន់កាប់អំណាចតាមមូលដ្ឋាន តាមថ្នាក់ផ្សេងៗ ម្នាក់ៗសុទ្ធតែមានខ្សែរបស់ខ្លួន តាមប្រពៃណីនៃសង្គមខ្មែរផង តាមមូលហេតុផ្សេងៗផង។ គឺមានអ្នកដែលដើរតាមខ្លួនដោយចង់បានអំណាចឬផលប្រយោជន៍ផ្សេងៗ ឬជាសាច់ ជាញាតិដែលធ្លៀតស៊ីបុណ្យដោយសារខ្លួន ឬជួនណាដោយសារភារៈកិច្ចតម្រូវឲ្យមកធ្វើការជាមួយក៏មាន។ លោកហ្វីលិព ហ្សត បានឃើញបញ្ហានេះច្បាស់នៅពេលដែលគាត់សរសេរថា: "...ការទាក់ទងតាមរបៀបសក្តិភូមិ ពីមេទៅ*

---

*លោកឌឿននៅ ក៏ប៉ងមានតួនាទីជាជំនួយការរបស់លោក ស្រាប់ហើយទៀត។ គួរគូសបញ្ជាក់ថា ដើម្បីធ្វើការងារដូចជាការងាររបស់លោកឌឿននេះ ត្រូវការកម្មាភិបាលដែលចូលជិតស្និទ្ធជាមួយកម្មាភិបាលនៅតាមមូលដ្ឋាន ឬអង្គភាពផ្សេងៗទៀតណាស់ ដឹងរាក់ជ្រៅពីគេទាំងឡាយ ច្រើនហួបបាយដេកលេងជាមួយគេបាន ព្រោះការងារនេះតម្រូវឲ្យជួយគណៈអចិន្ត្រៃយ៍តាមដានកម្មាភិបាលផ្សេងៗដែលជាប់សង្ស័យ ឬសាកសួរកម្មាភិបាលផ្សេងៗជុំវិញរឿងអ្វីមួយដែលគណៈអចិន្ត្រៃយ៍ត្រូវការតាមដាន។ (ការងារនេះ ក៏ខ្ញុំទើបតែដឹងដោយខ្ញុំស្រាវជ្រាវក្រោយមកនេះទេ)។ ដូច្នេះខ្ញុំជាបញ្ញាជនជាន់ខ្ពស់ មិនធ្លាប់ធ្វើការងារមូលដ្ឋាន មិនសូវស្គាល់កម្មាភិបាលមូលដ្ឋានផ្សេងៗឲ្យបានជិតស្និទ្ធជ្រៅជ្រះដូចលោកឌឿននិងប៉ងនោះទេ។ គេមិនត្រូវការខ្ញុំឲ្យមកធ្វើការងាររបៀបនេះទេ។ ខ្ញុំគ្រាន់តែធ្លៀតឱកាស បញ្ជាក់តែប៉ុណ្ណេះ។*



*កូន ចាក់ឬសជ្រាលជ្រៅណាស់នៅក្នុងសង្គមកម្ពុជា ដែលខ្មែរក្រហមខ្លួនឯងមិនទាន់អាចគាស់រំលើងបាននៅឡើយ[១៥៤]។*

*ឯមូលហេតុដែលនាំឲ្យពិបាកគាស់រំលើង គឺមកពីធាតុជាស្តេចត្រាញ់នៃប្រធានភូមិភាគទាំងប្រាំមួយ ដូចដែលលោកហ្វីលិព ហ្សតបាននិយាយយ៉ាងពិស្តារមកហើយ។ សភាពការណ៍នេះម៉្យាងវាជាឧបសគ្គនាំឲ្យពិបាកគាស់រំលើងសង្គមសក្តិភូមិ តែម៉្យាងទៀតដោយគេមានលក្ខណៈឯងឹតឯងល់ឃោរឃៅ និងមើលងាយជីវិតមនុស្ស "ដូចពួកឥស្សរៈកាលពី៣០ឆ្នាំមុន" គេក៏ជាប្រភពនៃការរំលោភបំពានគ្រប់បែបយ៉ាង ទាំងនៅពេលដែលត្រូវស្រាវជ្រាវរកខ្សែ អ្នកដែលត្រូវចាប់ទាំងនៅពេលដែលគេផ្តើមគំនិតចាប់ចងដោយខ្លួនគេ។*

*នេះហើយ ដែលនាំឲ្យកើតមានរឿងចាប់ចងដោយឯងឹតឯងល់ ស្អីក៏ក្បត់ៗ ឃ្លានពេកគាស់ដំឡូងមួយមើមដុតហូបក៏ក្បត់ កូន ឬ ប្រពន្ធ ឬ ប្តី ឬឪពុក ឬ ម្តាយឈឺ លួចអង្ករមួយក្តាប់មកបបរឲ្យហូបក៏ក្បត់...។ល។ នេះហើយជាប្រភពនៃពាក្យស្លោកដូចជា "ទុកក៏មិនចំណេញ ដកចេញក៏មិនខាត"...។ល។*

*២-ពិតហើយ ការជម្លៀសប្រជាជនពីទីក្រុង ការពង្រីកសហករណ៍កម្រិតខ្ពស់ ដោយប្រញាប់ប្រញាល់ គ្មានពេលពិនិត្យពិច័យ គ្មានពេលជ្រើសរើសសម្រិតសម្រាំង អប់រំកសាងប្រធានសហករណ៍ ការមិនចាយលុយ ការបន្តគ្រប់គ្រងប្រទេស ដូចកាលពីនៅក្នុងសង្គ្រាមដោយមានលក្ខការណ៍សម្ងាត់មានរបាំងតឹងរឹង មិនឲ្យនិយាយអ្វីប្រាប់គ្នាទៅវិញទៅមក បានបន្តិចបន្តួចជាការផ្តល់អំណាចធំសម្បើម ថែមទៀតដល់ស្តេចត្រាញ់ទាំងនោះ។*

*ប៉ុន្តែយើងមិនត្រូវភ្លេចទេថាមុន និងរំដោះភ្នំពេញ មានបញ្ហាពីរដែលចោទចំពោះមុខប.ក.ក. និងលោកប៉ុលពតជាបន្ទាន់ទៅហើយ ហើយបញ្ហាទាំងពីរសុទ្ធតែធ្ងន់ធ្ងរ ទាក់ទងដល់អាយុជីវិតជាតិ ៖*

---

*[១៥៤] ហ្វីលិព ហ្សត "ប៉ុល ពត..." ទំព័រ៣២០*

បញ្ហាទី១- គ្រោះអាសន្នមកពីការគម្រាមកំហែងរបស់វៀតណាម ដែលមានមហិច្ឆតាចង់គ្រប់គ្រងកម្ពុជា។ គ្រោះអាសន្ននេះ សកម្មភាពជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់ ប.ក.ក. ដូចបានរៀបរាប់ហូរហែរមកពីខាងលើនេះ បានបញ្ជាក់ឲ្យយើងឃើញច្បាស់អស់ហើយ។

បញ្ហាទី២- គ្រោះអាសន្នមកពីការអត់បាយ ដាច់ពោះនៅភ្នំពេញ និងទីរួមខេត្តផ្សេងទៀត ក៏ជាបញ្ហាដែលត្រូវគិតគូរដោះស្រាយជាបន្ទាន់ផងទៀត តាំងពីមិនទាន់រំដោះទូទាំងប្រទេសម៉េះ។

យើងមិនត្រូវភ្លេចផងទេថា សង្គ្រាមដែលបានដុតកំឡោចប្រទេសយើង៥ឆ្នាំមកនេះជាសង្គ្រាមហិនហោច។ ជនបទមួយផ្នែកធំត្រូវបានខ្ទេចខ្ទីដោយការទម្លាក់គ្រាប់បែក។ ឧទាហរណ៍ នៅជុំវិញភ្នំពេញ និង ទីរួមខេត្តនៅទាំងសង្ខាងដងទន្លេមេគង្គក្រោមរហូតទៅទល់ និងព្រំដែនវៀតណាម ភូមិសាស្ត្រគឺពោរពេញទៅដោយរណ្ដៅបេ៥២ ហើយថែមទាំងមានគ្រាប់បែកដែលមិនទាន់ផ្ទុះជាច្រើនថែមទៀត។ ដូច្នេះដីតំបន់ទាំងនោះ ត្រូវបោះបង់ចោល។ ឯនៅតំបន់ប្រទាញប្រទង់ក៏ធ្វើស្រែមិនបាន ពីព្រោះមានការប្រយុទ្ធគ្នា សារចុះសារឡើងអស់ពេលយ៉ាងយូរ ដើម្បីដណ្ដើមកន្លែងនោះ។ នៅកន្លែងជាច្រើនទៀតនៅពីក្រោយតំបន់ប្រទង់ប្រទាញជួនណាធ្វើស្រែបានហើយ ស្រូវនោះក៏ត្រូវខូចខាតទៅវិញ ដោយពេលខ្លះក៏កម្លាំងខ្មាំងនៅធ្លាក់ ចូលមកបាន ដើម្បីតែបំផ្លាញស្រូវដែលកំពុងឱនដាក់គ្រាប់។ ដូច្នេះនៅជនបទក៏មានការខ្វះខាតស្បៀង។ ថែមពីលើនេះ ត្រូវបំប៉នកងទ័ពឲ្យហូបបានគ្រប់គ្រាន់ថែមទៀតដើម្បីមានកម្លាំងទៅប្រយុទ្ធ។ ដូច្នេះប្រជាជនទូទៅហូបមិនបានឆ្អែតទេ។ គ្រាន់តែមិនចោទបញ្ហាអត់បាយដាច់ពោះតែប៉ុណ្ណោះ ពីព្រោះមានសហករណ៍ចែកគ្នាហូប។ ម្យ៉ាងទៀតជាទូទៅប្រជាជន រួមទាំងគ្រួសារខ្ញុំផង ហូបក្ដួច ឬអង្ករចេកជាមូលដ្ឋាន ដោយលាយជាមួយបាយមួយគ្រាប់ៗតែប៉ុណ្ណោះ។ ចំណែកឯនៅភ្នំពេញវិញ មានគ្រោះអាសន្នអត់បាយដាច់ពោះតាំងពីមួយឆ្នាំមុន ថ្ងៃ១៧មេសា១៩៧៥ម៉េះ។ នេះហើយដែលនាំឲ្យលោក ហ្សូវគ្រូស សរសេរថា ៖



"នៅខែមេសា១៩៧៥ រដ្ឋាភិបាលណាក៏ត្រូវតែប្រឈមមុខ និងបញ្ហាស្បៀង និងបញ្ហាកសិកម្ម ដែលសឹងតែដោះស្រាយមិនបាន..."។ សេចក្ដីរាយការណ៍មួយ ដែលផ្នែកទទួលខុសត្រូវខាងជំនួយបរទេស របស់អាមេរិកមានសរសេរថា: "ដើម្បីគេចឲ្យផុតពីការអត់បាយដាច់ពោះ ប្រទេសកម្ពុជាត្រូវការរំសាយដាវរបស់ពួកគេ ដើម្បីយកដែកមកធ្វើជានង្គ័ល តែគេមិនសូវសង្ឃឹមថាគេអាច ឬ ចង់ធ្វើដូច្នេះនោះទេ... ដូច្នេះ បើគ្មានជំនួយពីខាងក្រៅជាម្ហូបអាហារ និង ជាសម្ភារៈឲ្យបានគ្រាសក្រាលទេ ទុរភិក្សនឹងរីករាលដាលទូទាំងប្រទេស ចាប់ពីខែកុម្ភៈនេះទៅហើយ... ឆ្នាំនេះជាការជៀសមិនផុតទេប្រជាជនពាក់កណ្ដាលនឹងត្រូវធ្វើការដូចទាសករ ដោយមានបាយហូបតែបន្តិចបន្តួចប៉ុណ្ណោះ។ (ហើយអ្នកដែលបានគាំទ្ររបបសាធារណរដ្ឋរបស់លោកលន់ នល់ អាចលំបាកជាងនេះទៅទៀត)។ ការលំបាកលំបិន និងការអត់ឃ្លាននេះនឹងត្រូវបន្តដល់ទៅពីរ ឬ បីឆ្នាំទៅមុខទៀត"។[១៥៥]

អំពីសភាពការណ៍នៅភ្នំពេញ ដែលនិងត្រូវធ្លាក់មកនៅក្រោមការទទួលខុសត្រូវរបស់ខ្មែរក្រហមក្នុងពេលឆាប់ៗខាងមុខនេះ គាត់បានសរសេរដូចតទៅ ៖

"សេចក្ដីរាយការណ៍របស់អង្គការជួយសង្គ្រោះផ្សេងៗ និងការស៊ើបអង្កេតរបស់អង្គការសុខភាពពិភពលោក និង អនុកម្មការនៃជនភៀសខ្លួនរបស់ព្រឹទ្ធសភាបានបង្ហាញថា ការខ្វះម្ហូបអាហារចោទជាបញ្ហាធ្ងន់ធ្ងរតាំងពីឆ្នាំ១៩៧៤ម៉េះ។ ផ្នែកត្រួតពិនិត្យទូទៅនៃជំនួយបរទេសនៃក្រសួងការបរទេសបានគូសសង្កត់ថា កូនក្មេងកំពុងតែស្លាប់នៅស្រុកខ្មែរ...។ សេចក្ដីរាយការណ៍កត់សម្គាល់ថា៖ "គេតែងតែជួបប្រទះឃើញកូនក្មេងដែលរូបរាងកាយរាស្ងិតប្រជីវ ឃើញតែស្បែក និងឆ្អឹង នៅលើដៃសង្គមស្ងិតរបស់ម្ដាយអង្គុយនៅក្បៀនជញ្ជាំងតែម្នាក់ឯង គ្មាននរណាអើពើដល់ទេ ចាំតែថ្ងៃស្លាប់តែប៉ុណ្ណោះ..."។[១៥៦]

---

[១៥៥] វីលីយ៉ាំ ហ្សូវគ្រូស "ទុក្ខសោកវេទនាមួយដែលគ្មាននរណាគិតគូរដល់" ទំព័រ៣៧៥

[១៥៦] វីលីយ៉ាំ ហ្សូវគ្រូស "ទុក្ខសោកវេទនាមួយដែលគ្មាននរណាគិតគូរដល់" ទំព័រ៣៥១

ផ្អែកលើអង្គការសុខភាពពិភពលោកដដែលនេះ ហីលដីប្រាន់ និងពរទ័របានបង្ហាញថា ៥ខែមុនចប់សង្គ្រាម មានមនុស្ស១៥.០០០អត់បាយដាច់ពោះស្លាប់ទៅហើយ ក្នុងនេះភាគច្រើនជាជនភៀសខ្លួនមកពីជនបទៗ[១៩៧] ម៉្យាងទៀត ព្រឹត្តប័ត្រសាំរព័ត៌មាននៃសាធារណៈរដ្ឋខ្មែរលេខ២៩ ខែមីនា ១៩៧៥ បានផ្សាយថា ជារៀងរាល់ថ្ងៃមនុស្សរាប់រយនាក់ស្លាប់ដោយអត់បាយដាច់ពោះ។

ចំណែកឯលោកហ្វីលិព ហ្សុតវិញគាត់បានសរសេរដូចតទៅ៖

"អ្នកភូមិ រាប់រយពាន់នាក់បានរត់ចូលខេត្ត។ នៅទីនោះគេរស់នៅក្នុងសភាពលំបាកតោកយ៉ាកខ្លាំងណាស់ ក្បែរៗមាត់ជ្រោះនៃគ្រោះអាសន្នអត់បាយដាច់ពោះស្លាប់។ ប្រជាជនភ្នំពេញដែលមានតែប្រាំមួយរយហាសិបពាន់នាក់នៅពេលរដ្ឋប្រហារ បានកើនឡើងហួសពី១លាននាក់ នៅពេលចុងឆ្នាំ ហើយដល់ពីរលានកន្លះនៅឆ្នាំ១៩៧៥ (លោកហ្សូវក្រុស បាននិយាយថា ដល់ទៅបីលាននាក់)។ ទីរួមខេត្តដែលនៅក្នុងកណ្ដាប់ដៃរបស់រដ្ឋាភិបាលនៅឡើយដូចជា បាត់ដំបង កំពង់ធំ និងសៀមរាប មនុស្សណែនណាន់តាន់តាប់ រកកល់តែនិងផ្ទុះ"។[១៩៨]

លោកមីកាអែលវិកឺរី លោកក៏បានជូនសភាពការណ៍មិនខុសពីខាងលើនេះដែរ។ លោកបានដកស្រង់អត្ថបទនៃទស្សនាវដ្ដីអង់គ្លេសឈ្មោះសឺនដេថៃម៍ម៉ាហ្គាស៊ីនដែលសរសេរថា... "(គ្រាន់តែនៅភ្នំពេញ) ឥឡូវនេះកូនង៉ែតស្លាប់៥០នាក់ក្នុងមួយអាទិត្យ ដោយសារតែការខ្វះអាហារ ហើយកូនក្មេង ផ្សេងទៀត រកមើលមិនយល់ទេ ដោយសារតែអត់បាយ"។

ចំណែកឯផ្ទាល់ខ្លួនលោក លោកសរតសេរដូចតទៅ៖

នៅឆ្នាំ១៩៧៤ នៅភ្នំពេញការផ្ដល់អង្ករបានប្រហែលតែមួយភាគបីនៃចំនួនដែលចាំបាច់ទេ។ ហើយក្រោយខែកញ្ញាឆ្នាំនោះ ជាមធ្យមមេគ្រួសារ

[១៩៧] ហីលដីប្រាន់ និង ពរទ័រ "កម្ពុជាការអត់បាយដាច់ពោះ" ១៩៧៦ ទំព័រ២៩

[១៩៨] ហ្វីលីព ហ្សុត "ប៉ុល ពត..." ទំព័រ២១៦



នីមួយៗរកមិនបានគ្រប់ដើម្បីទិញ (អង្ករ) មិនបានគ្រប់ចំនួនដែលចាំបាច់ទេ ហើយមិនច្បាស់ជាមានលក់ផងទេ។ នៅខែកុម្ភ១៩៧៥ គ្រួសារនីមួយៗត្រូវបានអនុញ្ញាតឲ្យទិញបានតែ២.៧៥គីឡូសម្រាប់ម្នាក់ៗ សម្រាប់១០ថ្ងៃតាមថ្ងៃដែលរដ្ឋជួយឧបត្ថម្ភ។ មានន័យថា ២៧០ក្រាមមួយថ្ងៃ គឺលើសពីមួយកំប៉ុងបន្តិចៗ ប៉ុន្តែមិនត្រូវភ្លេចអំពើពុករលួយនៃរបបលោកលន់នល់ និងការបង្វែរស្បៀង ដែលជាញយៗ នាំឲ្យរកទិញចំនួនស្បៀងអប្បបរិមាដែលរដ្ឋអនុញ្ញាតហើយនោះ មិនបានទៀតផងនោះទេ។ មានតែអ្នកមានទេដែលគេហូបគ្រប់គ្រាន់។ ...នៅខែមិនា១៩៧៥ មានមនុស្ស៨ពាន់នាក់ស្លាប់ដោយអត់បាយ។ ជនខាងលិចម្នាក់ដែលបានប្រមូលស្ថិតិខាងលើនេះបាននិយាយថា ៖ "ក្មេងជំនាន់នេះ និង ត្រូវជាជំនាន់ដែលបាត់បង់ហើយ"។... ហើយលោក វិការីសន្និដ្ឋានជាបញ្ចប់ថា៖ ...មានការពិតច្រើនក្នុងការដែលកម្ពុជាប្រជាធិបតេយ្យអះអាងថា មានតែជម្លៀសទេ ទើបអាចសង្គ្រោះប្រជាជនទីក្រុង ពីគ្រោះអាសន្នអត់បាយដាច់ពោះធូនធូរបាន...។[១៩៩]

សរុបមក នៅឆ្នាំ១៩៧៥ បញ្ហាស្បៀងទូទាំងប្រទេសមានដូចតទៅ: នៅជនបទ ជាយូរមកហើយដែរ ដីមួយផ្នែកធំត្រូវបោះចោល ធ្វើស្រែមិនបាន។ ប្រជាជន៣លាននាក់ ជាទូទៅ ហូបមិនឆ្អែតទេ។ ឯនៅទីក្រុងមនុស្ស ៣លាននាក់ទៀតអត់បាយដាច់ពោះបណ្ដើរៗហើយ។ ដូច្នេះហើយបានជាលោកប៉ុលពតនិយាយថា: "បន្តនៅក្នុងក្រុង នាំឲ្យមានគ្រោះអាសន្នទុរភិក្ស។ ដូច្នេះជម្លៀសចេញពីទីក្រុងវិញល្អជាង ដើម្បីជៀសវាងទាំងគ្រោះអាសន្នទុរភិក្សទាំងគ្រោះអាសន្នបះបោរ"[២០០]។ បើមានការបះបោរហើយ វៀតណាមច្បាស់ជាចូលមកអន្តរាគមន៍ហើយ។ តែដោយមិនឃើញមានការបះបោរ វៀតណាម ក៏បែរជាដាក់ឱសានវាទ នៅឆ្នាំ១៩៧៦វិញ។

[១៩៩] មីកាអែលវីកឺរី "កម្ពុជា ១៩៧៥-១៩៨២" ទំព័រ៨៤ និង ៨៥

[២០០] សម្ភាសន៍ជាមួយលោក ណោតថៃយ័រ ឆ្នាំ១៩៨៨